*The Restoration of All Things*

Copyright © 2012 by The Gospel Coalition

Published by Crossway

a publishing ministry of Good News Publishers

Wheaton, Illinois 60187, U.S.A.

This edition published by arrangement with Crossway.

All rights reserved.

This project was accomplished in partnership with The Gospel Coalition International Outreach.

# ការស្គាល់របស់សព្វសារពើឡើងវិញ

លោក សាំ ស្ទម Sam Storms

មាតិកា

ការមកដល់ជាដំបូងរបស់នគរព្រះ និងការធ្វើឲ្យគ្រប់លក្ខណ៍នៅគ្រាចុងក្រោយបំផុតរបស់នគរព្រះ ................3

ការរស់ឡើងវិញ.......................................................................................................6

ការវិនិច្ឆ័យ...........................................................................................................9

ស្ថាននរក និងការដាក់ទណ្ឌកម្មអស់កល្បជានិច្ច.......................................................11

ស្ថានសួគ៌នៅលើផែនដី..........................................................................................13

ការសន្និដ្ឋាន........................................................................................................16

កំណត់..................................................................................................................17

«ព្រះគ្រីស្ទបានសុគត ព្រះគ្រីស្ទបានរស់ឡើងវិញ ព្រះគ្រីស្ទនឹងយាងត្រឡប់មកវិញ!»។ ការនេះរំឭកយើងអំពីសេចក្ដីពិតសំខាន់បំផុតដែលថា ដំណឹងល្អគឺជាមូលដ្ឋានគ្រឹះនៃអនាគតរបស់យើង។ សេចក្ដីពិតដែលថា ព្រះគ្រីស្ទ «បានសុគត» ហើយ «បានរស់ឡើងវិញ» នៅក្នុងប្រវត្តិសាស្ត្រគឺជាមូលដ្ឋានគ្រឹះដែលគ្រីស្ទបរិស័ទទ្រាំទ្រដោយសេចក្ដីសង្ឃឹមថា « ព្រះគ្រីស្ទនឹងយាងមកវិញម្ដងទៀត»។ អ្វីដែលព្រះបានសម្រេចរួចហើយនៅក្នុងអតីតកាលតាមរយៈជីវិត ការសុគត និងការរស់ឡើងវិញរបស់ព្រះរាជបុត្រារបស់ទ្រង់គឺជាមូលដ្ឋានគ្រឹះសម្រាប់អ្វីដែលព្រះគម្ពីរបាននិយាយថា ទ្រង់នឹងធ្វើនៅគ្រាអនាគត គឺនៅក្នុងការដែលធ្វើឲ្យគ្រប់លក្ខណ៍ជាគ្រាចុងក្រោយនោះ។

សេចក្ដីសង្ឃឹមរបស់គ្រីស្ទបរិស័ទមិនមែនជាសេចក្ដី ប្រាថ្នាសម្រាប់អនាគតដែលប្រហែលជានឹងមិនសម្រេចនោះទេ។ ប៉ុន្តែគឺជាការរំពឹងទុកដែលមានទំនុកចិត្ត ដែលចាក់ឫសនៅក្នុងអ្វីដែលបានកើតឡើងពីរពាន់ឆ្នាំកន្លងទៅហើយ។ ការងារប្រោសលោះរបស់ព្រះគ្រីស្ទបានមានប្រសិទ្ធិភាពនិងបានបញ្ចប់។ ការនោះរួមទាំងការរស់ឡើងវិញនិងការលើកតម្កើងជាព្រះអម្ចាស់របស់ទ្រង់ទៅឯខាងស្តាំព្រះហស្តរបស់ព្រះ វរបិតា គឺជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់ការទាំងអស់ដែលពួកគ្រីស្ទបរិស័ទសង្ឃឹមចង់បាននៅពេលព្រះគ្រីស្ទយាងត្រឡប់មកវិញ ហើយនិងការបំពេញសម្រេចការធ្វើឲ្យគ្រប់លក្ខណ៍នៃគោលបំណងដ៏នៅអស់កល្បជានិច្ចរបស់ព្រះនៅក្នុងផ្ទៃមេឃថ្មីនិងផែនដីថ្មី។

សេចក្ដីថ្លែងការណ៍អំពីសេចក្ដីជំនឿរបស់*ក្រុមចម្រុះដំណឹងល្អ* (The Gospel Coalition) ក្នុងមាត្រាទីដប់បី បានសង្ខេបសេចក្ដីសង្ឃឹមរបស់គ្រីស្ទបរិស័ទបានយ៉ាងល្អ។ សេចក្ដីថ្លែងការណ៍នេះមិនសរសេរអំពីទស្សនៈខុសៗគ្នាក្នុងចំណោមអ្នកចលនាដំណឹងល្អអំពីអនាគតនោះទេ ប៉ុន្តែសេចក្ដីថ្លែងការណ៍នេះមានបំណងពន្យល់អំពីធាតុសំខាន់ៗនៃសេចក្ដីសង្ឃឹមរបស់យើងដែលអស់អ្នកដែលជឿលើអំណាចរបស់ព្រះគម្ពីរ បានជឿ។ ដូច្នេះ វាគឺជាសេចក្ដីថ្លែងការណ៍របស់ចលនាដំណឹងល្អដែលជៀសវាងទស្សនៈខុសៗគ្នាដែលជារឿយៗបានធ្វើឲ្យខូចការពិភាក្សាអំពីគោលបំណងចុងក្រោយរបស់ព្រះ។ សេចក្ដីថ្លែងនេះថ្លែងដូចតទៅថា:

យើងជឿថាអង្គព្រះយេស៊ូវផ្ទាល់នឹងយាងត្រលប់មកវិញមានព្រះកាយប្រកបដោយសិរីរុងរឿងរួមជាមួយនឹងពួកទេវតាបរិសុទ្ធរបស់ទ្រង់គឺជាពេលដែលទ្រង់នឹងធ្វើជាចៅក្រមចុងក្រោយបំផុតហើយនគរទ្រង់នឹងបានសម្រេចពេញលេញ។យើងជឿថាទាំងពួកសុចរិតនិងពួកទុច្ចរិតនឹងរស់ឡើងវិញខាងរូបកាយគឺពួកអ្នកទុច្ចរិតនឹងជាប់ជំនុំជម្រះហើយជាប់ទោសដោយដឹងខ្លួនក្នុងស្ថាននរកអស់កល្បជានិច្ចដូចដែលព្រះអម្ចាស់នៃយើងទ្រង់បានបង្រៀនហើយ។រីឯពួកសុចរិតវិញគេនឹងទទួលបានព្រះពរអស់កល្បជានិច្ចនៅក្នុងវត្តមាននៃព្រះដែលគង់លើបល្ល័ង្កនិងនៃកូនចៀមនៅក្នុងផ្ទៃមេឃថ្មីនិងផែនដីថ្មីដែលជាលំនៅនៃសេចក្តីសុចរិត។នៅថ្ងៃនោះពួកជំនុំនឹងត្រូវបង្ហាញថាជាអ្នកគ្មានកំហុសនៅចំពោះព្រះដោយសារការស្តាប់បង្គាប់ការរងទុក្ខនិងជ័យជំនះរបស់ព្រះគ្រីស្ទគឺគ្រប់ទាំងអំពើបាបត្រូវបានសម្អាតហើយលទ្ធផលដ៏អាក្រក់ទាំងអស់របស់បាបក៏នឹងត្រូវបានបំបាត់ចោលអស់កល្បជានិច្ច។ព្រះទ្រង់នឹងធ្វើជាគ្រប់ទាំងអស់ក្នុងគ្រប់ទាំងអស់ហើយពួករាស្ត្រទ្រង់នឹងរីករាយនៅក្នុងវត្តមាននៃសេចក្តីបរិសុទ្ធដ៏រកថ្លែងមិនបានរបស់ទ្រង់ហើយគ្រប់ការទាំងអស់នឹងបានជាការសរសើរតម្កើងពីព្រះគុណដ៏មានសិរីល្អរបស់ទ្រង់។

## *ការមកដល់ជាដំបូងរបស់នគរព្រះ និងការធ្វើឲ្យគ្រប់លក្ខណ៍នៅគ្រាចុងក្រោយបំផុតរបស់នគរព្រះ*

«ដំណើរលេចមកនៃសិរីល្អរបស់ព្រះដ៏ជាធំនិងព្រះយេស៊ូវគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់យើង»[៧] (ទីតុស ២:១៣) គឺជាពេលទ្រង់នឹងធ្វើឲ្យនគរព្រះបានគ្រប់លក្ខណ៍។ នេះជាសេចក្តីសង្ឃឹមរបស់គ្រីស្ទបរិស័ទហើយជាផ្ទៃរឿងចំបងនៃអ្វីដែលព្រះគម្ពីរបង្រៀនអំពីអនាគត។ ដើម្បីឲ្យយល់អំពីនេះ ដំបូងយើងត្រូវតែសិក្សាអំពីការចាប់ផ្តើមការគ្រប់គ្រងដែលប្រកបដោយអធិបតីភាពរបស់ព្រះ ក្នុងពេលព្រះគ្រីស្ទយាងមកជាលើកដំបូង។ ដូចជាយើងបានកត់សំគាល់ខាងលើហើយ ទីនេះយើងឃើញម្តងទៀតថា អតីតកាលគឺជាគន្លឹះជួយអោយយើងយល់អំពីអនាគត។

ការយល់អំពីសេចក្តីសង្ឃឹមរបស់ពួកយូដានៅក្នុងសតវត្សទីមួយនឹងជួយឲ្យយើងយល់អំពីការប្រកាសរបស់ព្រះគ្រីស្ទអំពីនគរព្រះ។ ជនជាតិអ៊ីស្រាអែលនៅសតវត្សទីមួយសង្ឃឹមចង់បានអំណាចគ្រប់គ្រងទឹកដី ដែលព្រះបានសន្យាចំពោះអ័ប្រាហាំនិងពូជពង្សរបស់គាត់ រួមទាំងរាជ្យបល្ល័ង្កដ៏អស់កល្បជានិច្ច ឧត្តមភាពខ្លាំងបំផុតជាអន្តរជាតិ ហើយសំខាន់លើសជាងនេះគឺវត្តមានរបស់ស្តេចអង្គទ្រង់ក្នុងការគ្រប់គ្រងរាស្ត្ររបស់ព្រះដោយអំណាចនិងសិរីល្អ។ នៅសម័យព្រះយេស៊ូវ ជនជាតិយូដាបានសួរថា «តើពេលណាព្រះយ៉ាវេនឹងបញ្ជូនព្រះមែស៊ីមករំដោះយើងចេញពីពួកអ្នកកៀបសង្កត់យើង ហើយបំពេញសម្រេចសេចក្តីសន្យាសម្ព័ន្ធមេត្រីដែលទ្រង់បានប្រទានឲ្យព្ធយុកោរបស់យើង? តើការបំពេញសម្រេចនគរដែលព្រះបានសន្យានៅឯណា?»

គ្មានអ្នកណាជំទាស់នឹងសេចក្តីពិតដែលថា ការផ្តោតលើព័ន្ធកិច្ចរបស់ព្រះគ្រីស្ទគឺជាការប្រកាសអំពីការមកដល់របស់នគរព្រះនោះឡើយៈ «ពេលវេលាបានសម្រេចហើយ នគរព្រះជិតមកដល់ ដូច្នេះ ចូរប្រែចិត្តហើយជឿដំណឹងល្អចុះ» (ម៉ាកុស ១:១៥ សូមមើលផងដែរ ម៉ាថាយ ៣:២, ៤:១៧, ២៣, ១០:៧; លូកា ៤:៤៣, ១០:៩)។ ពួកយូដាក្នុងព្រះគម្ពីរសញ្ញាចាស់ជារឿយៗបានគិតថា នគរព្រះគឺជាការដែលព្រះអង្គច្បាំងឈ្នះពួកខ្មាំងសត្រូវរបស់ទ្រង់និងការស្តាររាស្ត្ររបស់ព្រះដែលជាអ៊ីស្រាអែលឡើងវិញ ទៅកាន់ឧត្តមភាពខ្ពស់បំផុតនៅក្នុងទឹកដី និងការបំពេញសម្រេចសេចក្តីសន្យាអំពីបល្ល័ង្កតាមរយៈរាជ្យដាវីឌ ហើយគ្រង់គ្រងផែនដីដោយអំណាចនិងសិរីល្អ។

លោក រ៉ៃតN. T. Wright សរសេរថា «សម្រាប់ពួកយូដានៅក្នុងពាក់កណ្តាលដំបូងនៃសតវត្សទីមួយ នគរព្រះបានមានន័យថា ការរំដោះឲ្យរួចដែលនឹងមកដល់របស់អ៊ីស្រាអែល ជ័យជំនះលើពួកអ្នកកាន់សាសនាដទៃ សន្តិភាពយុត្តិធម៌និងសេចក្តីចម្រុងចម្រើន។ វាមិនភ្ញាក់ផ្អើលទេថា មនុស្សអន្ទះសារចង់ស្តាប់ហោរាម្នាក់បានលេចមកប្រកាសថា នគរនេះបាន

កំពុងចាប់ផ្ដើម ហើយថា ព្រះរបស់អ៊ីស្រាអែលកំពុងក្លាយជាស្ដេចឥឡូវនេះហើយ»។[២]សំនួរសំខាន់គឺ តើពេលណាព្រះយ៉ាវ៉េនឹងយាងត្រឡប់មកស៊ីយ៉ូនដើម្បីគង់នៅជាមួយរាស្ត្ររបស់ទ្រង់ អត់ទោសនិងស្ដារពួកគេឡើងវិញ? លោក រ៉ែត សរសេរថា សេចក្ដីសង្ឃឹមរបស់ជនជាតិយូដា

> ផ្ដោតលើមនុស្សទាំងស្រុង។ បើសិនពីឡាតកំពុងគ្រប់គ្រងស្រុកយូដា នោះនគរព្រះមិនបានមកដល់ទេ។ បើសិនព្រះវិហារមិនត្រូវបានសាងសង់ឡើងវិញទេ នោះនគរព្រះក៏មិនបានមកដល់ដែរ។ បើសិនព្រះមែស៊ីមិនបានយាងមកទេ នោះនគរព្រះក៏មិនបានមកដល់ដែរ។ បើសិនអ៊ីស្រាអែលមិនគោរពតាមព្រះគម្ពីរតូរ៉ា(បញ្ញកណ្ឌក្រិត្យវិន័យ)ឲ្យបានត្រឹមត្រូវទេ នោះនគរព្រះក៏មិនបានមកដល់ដែរ។ បើសិនពួកអ្នកកាន់សាសនាដទៃមិនបានចាញ់ ឬមកទទួលសេចក្ដីបង្រៀននៅស៊ីយ៉ូនទេ នោះនគរព្រះក៏មិនបានមកដល់ផងដែរ។ ព្រឹត្តិការណ៍ទាំងនេះគឺចាំបាច់សម្រាប់នគរព្រះ។[៣]

សម្រាប់ពួកអ្នកដឹកនាំនិងមនុស្សធម្មតាក្នុងសម័យរបស់ព្រះយេស៊ូវ នគរដែលនឹងមកដល់របស់ព្រះនឹងនាំមកនូវការរំដោះជាតិនិងការយកឈ្នះខាងកំឡាំងទ័ពលើពួកអ្នកកៀបសង្កត់ដែលកាន់ខាងសាសនាដទៃ។ ទស្សនៈនេះឯងដែលបានធ្វើឲ្យលោកយ៉ូហានបាទីស្ទមានការយល់ច្រឡំអំពីព្រះយេស៊ូវៈ

> រីឯយ៉ូហានដែលជាប់នៅក្នុងគុកគាត់បានឮពីការទាំង ប៉ុន្មាន ដែលព្រះគ្រីស្ទទ្រង់ធ្វើ ហើយក៏ចាត់សិស្សគាត់២នាក់អោយទៅទូលសួរទ្រង់ថា តើទ្រង់ជាព្រះអង្គដែលត្រូវយាងមកនោះ ឬត្រូវអោយយើងខ្ញុំចាំ១អង្គទៅទៀត? ព្រះយេស៊ូវទ្រង់មានបន្ទូលតបថា ចូរទៅប្រាប់យ៉ូហាន ពីសេចក្ដីទាំងប៉ុន្មានដែលអ្នកកំពុងតែឮ ហើយឃើញចុះ គឺ ថា មនុស្សខ្វាក់បានភ្លឺ មនុស្សខ្វិនបានដើររួច មនុស្សឃ្លង់បានជាស្អាតមនុស្សថ្លង់បានឮ មនុស្សស្លាប់បានរស់ឡើងវិញ ហើយមនុស្សទាល់ក្របានឮដំណឹងល្អផង មានពរហើយ អ្នកណាដែលមិនរវាតចិត្តដោយព្រោះខ្ញុំ។ (ម៉ាថាយ ១១:២-៦)

ក្នុងការឆ្លើយតបចំពោះពួកសិស្សរបស់យ៉ូហានបាទីស្ទ ព្រះយេស៊ូវកំពុងអះអាងថា ទ្រង់កំពុងបំពេញសម្រេចសេចក្ដីសង្ឃឹមនៅក្នុងព្រះគម្ពីរសញ្ញាចាស់ដែលមានទាំងព្រះពរផង។ ប៉ុន្តែ ការបំពេញសម្រេចមិនបានកំពុងកើតដូចអ្វីដែលពួកគេបានគិតថាគួរតែកើតឡើងនោះទេ ដូច្នេះព័ន្ធកិច្ចរបស់ព្រះគ្រីស្ទបានធ្វើឲ្យយ៉ូហានបាទីស្ទងឿងឆ្ងល់។ នេះដោយព្រោះការបំពេញសម្រេចបានកំពុងកើតឡើងនៅក្នុងព្រះយេស៊ូវ ប៉ុន្តែមិនមានការដែលពួកគេកំពុងរង់ចាំនោះទេ។ នគររបស់ព្រះមែស៊ីដែលពួកហោរានៅក្នុងព្រះគម្ពីរសញ្ញាចាស់បានប្រកាសនឹងត្រូវមកដល់ហើយវាក៏កំពុងត្រូវបានបំពេញសម្រេចនៅក្នុងអង្គបុគ្គលនិងព័ន្ធកិច្ចរបស់ព្រះយេស៊ូវ ប៉ុន្តែមិនបានធ្វើឲ្យគ្រប់លក្ខណ៍នោះទេ។ ពួកយូដានៅក្នុងសម័យរបស់ព្រះយេស៊ូវ (យោងតាមអ្វីដែលពួកគេអាននៅក្នុងព្រះគម្ពីរសញ្ញាចាស់) ពួកគេរំពឹងចង់បានការធ្វើឲ្យគ្រប់លក្ខណ៍របស់នគរព្រះដែលជាការបញ្ចប់និងការផ្ដួលរំលំពួកខ្មាំងសត្រូវរបស់អ៊ីស្រាអែល ហើយនិងសម័យប្រកបដោយសន្តិភាពនិងសេចក្ដីចម្រុងចម្រើននៅក្នុងទឹកដីនៅចុងបញ្ចប់។

ទោះយ៉ាងណា ព្រះយេស៊ូវបានយាងមកហើយទ្រង់បានប្រកាសព្រះរាជសារថា មុននគរព្រះមកដល់ហើយបានគ្រប់លក្ខណ៍ នគរព្រះបានមកតាមរយៈទ្រង់និងការងាររបស់ទ្រង់ ដែលទ្រង់មានសមត្ថភាពធ្វើតាមរយៈព្រះវិញ្ញាណបរិសុទ្ធ និងឫទ្ធានុភាពរបស់ព្រះ។ ដូច្នេះ នគរព្រះគឺជាការសោយរាជ្យរបស់ព្រះខាងឯវិញ្ញាណពេលបច្ចុប្បន្ន និងអាណាចក្រនាពេលអនាគតដែលទ្រង់នឹងគ្រប់គ្រងដោយឫទ្ធានុភាពនិងសិរីល្អ។ ដូច្នេះ លោក ចច ឡែត George Ladd សន្និដ្ឋានបានយ៉ាងត្រឹមត្រូវថាៈ

> នៅមុនពេលនគរព្រះលេចមកនៅទីអវសានកាលនៃពិភពលោក នគរព្រះបានរីកចម្រើនក្នុងចំណោមមនុស្សតាមរយៈព្រះយេស៊ូវនិងបេសកកម្មរបស់ទ្រង់។ នគរព្រះនៅសម័យនេះមិនមែនគ្រាន់តែជាការគ្រប់គ្រងជាសកលរបស់ព្រះដែលមនុស្សត្រូវតែចុះចូលចំពោះគ្រប់ការទាំងអស់នោះទេ តែវាគឺជាឫទ្ធានុភាពមួយដែលធ្វើការក្នុងចំណោម

> មនុស្ស...ព្រះបានបើកសំដែងការគ្រប់គ្រងរបស់ទ្រង់ (នគររបស់ទ្រង់) ដើម្បីនាំមកឲ្យមនុស្សនូវព្រះពរនៃការសោយរាជ្យរបស់ទ្រង់នៅមុននគរព្រះមកដល់និងការបើកសំដែងចុងក្រោយអំពីការគ្រប់គ្រងរបស់ទ្រង់ក្នុងការបង្កើតថ្មី។[៤]

ក្នុងការឆ្លើយតបចំពោះសំនួររបស់យ៉ូហានបាទីស្ទ ព្រះយេស៊ូវបានចង្អុលទៅឯការជាប់ចំណងរបស់សាតាំងជាគំរូនៃការបើកសំដែងអំពីនគរព្រះ។ «ការដែលព្រះយេស៊ូវបណ្តេញអារក្សបង្ហាញថា នគរព្រះបានលុកលុយអាណាចក្ររបស់សាតាំង ហើយបានឈ្នះ ប៉ុន្តែជ័យជំនះរបស់ព្រះគ្រីស្ទមិនទាន់ពេញលេញទេ។ ថ្វីបើជ័យជំនះរបស់ព្រះគ្រីស្ទមិនទាន់បង្គ្រប់ទេជ័យជំនះរបស់ព្រះគ្រីស្ទក្នុងការបណ្តេញអារក្សជាភស្តុតាងថា ព្រះគ្រីស្ទនិងបំផ្លាញសេចក្តីអាក្រក់និងមារសាតាំងនៅពេលអនាគត»[៥] ព្រះបន្ទូលរបស់ព្រះយេស៊ូវបានបង្ហាញអំពីវត្តមានរបស់នគរព្រះ «ការដែលព្រះយេស៊ូវប្រកាសព្រះបន្ទូលបានបង្កើតឲ្យមាននូវអ្វីដែលទ្រង់បានប្រកាសនោះគឺ ដោះលែងអ្នកជាប់ចំណង ព្យាបាលអ្នកខ្វាក់ ដោះលែងអ្នកដែលគេកៀបសង្កត់....ព្រះរាជសារបង្កើតសម័យថ្មី...វាធ្វើឲ្យមានទីសំគាល់នៃការបំពេញសម្រេចរបស់ព្រះមែស៊ី។ ព្រះបន្ទូលធ្វើឲ្យនគរព្រះកើតឡើង។ ដំណឹងល្អគឺជាទីសំគាល់របស់ព្រះមែស៊ីដ៏ធំបំផុត»។[៦]

ដូច្នេះ នគរព្រះគឺជាការគ្រប់គ្រងរបស់ព្រះដែលប្រោសលោះមនុស្ស ឬជាអំណាចប្រកបដោយអធិបតីភាពរបស់ទ្រង់ដែលបង្កើតការគ្រប់គ្រងរបស់ទ្រង់ក្នុងចំណោមមនុស្ស។ មានកាលៈទេសៈពីរនៅក្នុងការបើកសំដែងអំពីនគរព្រះនេះ។ ទីមួយៈនៅពេលវាត្រូវបានបំពេញសម្រេចនៅក្នុងប្រវត្តិសាស្ត្រក្នុងការយាងមកលើកដំបូងរបស់ព្រះរាជបុត្រា ដែលសាតាំងត្រូវបានចាញ់ និងមនុស្សប្រុសមនុស្សស្រីបានទទួលនូវព្រះពរនៃការគ្រប់គ្រងរបស់ព្រះ ហើយទីពីរៈ នៅពេលវានឹងត្រូវបានធ្វើឲ្យគ្រប់លក្ខណ៍នៅទីអវសានកាលនៃពិភពលោកដោយការយាងមកជាលើកទីពីររបស់ព្រះរាជបុត្រា នៅពេលទ្រង់នឹងបំផ្លាញពួកខ្មាំងសត្រូវរបស់ទ្រង់ជារៀងរហូត ការសង្គ្រោះរាស្ត្ររបស់ទ្រង់និងរបស់សព្វសារពើពីការអាក្រក់ ហើយនិងការបង្កើតការគ្រប់គ្រងដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់នៅក្នុងផ្ទៃមេឃថ្មីនិងផែនដីថ្មី។

រឿងប្រៀបប្រដូចនៅក្នុងម៉ាថាយ ១៣ ពន្យល់បង្ហាញថា នគរព្រះដែលមកតាមរយៈព័ន្ធកិច្ចរបស់ព្រះយេស៊ូវខុសពីនគរព្រះដែលពួកយូដាគិតថានឹងមកដល់។ វាមិនមែនជាអាថ៌កំបាំងដែលថា នគរព្រះនឹងមក ហើយមកដោយឫទ្ធានុភាពនិងសិរីល្អនោះទេ។ សេចក្តីអាថ៌កំបាំងគឺជាការបើកបង្ហាញថ្មីមួយទាក់ទងនឹងគោលបំណងរបស់ព្រះសម្រាប់ការបង្កើតនគរមួយនោះ គឺថានគរនោះដែលនឹងមកនៅពេលអវសានកាលនៃពិភពលោកដោយឫទ្ធានុភាពនិងសិរីល្អបានចូលមកក្នុងលោកិយរួចទៅហើយនៅក្នុងទំរង់បិទបាំង ដើម្បីធ្វើការយ៉ាងអាថ៌កំបាំងនិងនៅក្នុងចំណោមមនុស្ស (សូមមើលម៉ាកុស ៤:២៦-៣២)។ លោក ឡែត ពន្យល់ម្តងទៀតដូច្នេះថាៈ

> យើងអាចសន្និដ្ឋានបានថា ûសេចក្តីអាថិកំបាំងអំពីនគរព្រះ™ គឺជាគន្លឹះសម្រាប់ការយល់អំពីសេចក្តីបង្រៀនរបស់ព្រះយេស៊ូវអំពីនគរព្រះ។ ទ្រង់បានប្រកាសថា នគរព្រះជិតមកដល់ហើយ គឺការពិត ទ្រង់បានបញ្ជាក់អះអាងថា នគរព្រះពិតជាបានមកក្នុងចំណោមមនុស្សមែន (ម៉ាថាយ ១២:២៨)។ នគរព្រះមានវត្តមាននៅក្នុងព្រះបន្ទូលរបស់ទ្រង់និងក្នុងការងារជាព្រះមែស៊ីរបស់ទ្រង់។ នគរព្រះមានវត្តមាននៅក្នុងអង្គបុគ្គលរបស់ទ្រង់ និងដោយសារព្រះមែស៊ីបានសង្គ្រោះមនុស្ស។ នគរព្រះបានបំពេញសម្រេចសេចក្តីសន្យានៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ប៉ុន្តែ យើងចាំបាច់ត្រូវទទួលការបើកសំដែងដើម្បីអោយយើងអាចយល់បានអំពីការមកដល់និងវត្តមានរបស់នគរព្រះ។ពីព្រោះថ្វីជ្បិតតែវត្តមានរបស់នគរព្រះគឺជាការបំពេញសម្រេចសេចក្តីសន្យានៅក្នុងព្រះគម្ពីរសញ្ញាចាស់ក៏ដោយ ក៏វាជាការបំពេញសម្រេចមួយនៅក្នុងរបៀបខុសគ្នាពីអ្វីដែលពួកយូដាបានគិតដោយសារតែការកាត់ស្រាយរបស់ពួកគេលើពួកហោរា។ ផែនការណ៍របស់ព្រះពីដើមដំបូងគឺ ព្រះអង្គនឹងផ្តួលរំលំនគររបស់សាតាំង និង ប្រោសលោះមនុស្សនៅពេលព្រះយេស៊ូវបានយាងមកលោកិយនៅសតវត្សរ៍ទីមួយ ហើយការទាំងនេះនឹងកើតឡើងមុននគរព្រះដែលពោរ

ពេញដោយព្រះចេស្តាដ៏រុងរឿងមកដល់នៅទីអវសានកាលនៃពិភពលោក។ ការបើកសំដែងថ្មីអំពីនគរព្រះនេះបានកំពុងកើតឡើងនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ហើយបានផ្តោតទៅលើមនុស្សម្នាក់ គឺព្រះយេស៊ូវគ្រីស្ទ។[៧]

ដូច្នេះ នគរព្រះបានសំដែងមកពីរដង ហើយការសំដែងពីរដងនេះ(ការយាងមកលើកទី១និងទី២របស់ព្រះគ្រីស្ទ)ជាការបើកសំដែងខុសប្លែកពីគ្នា។ ទ្រង់បានយាងមកលើកដំបូងដោយភាពមិនច្បាស់និងបន្ទាបខ្លួន ដើម្បីរងទុក្ខនិងសុគតសម្រាប់ការបង្ហាញភាពត្រឹមត្រូវនៃសេចក្តីសុចរិតរបស់ព្រះនិងសង្គ្រោះរាស្ត្ររបស់ទ្រង់ (រ៉ូម ៣:២៣-២៦)។ ប៉ុលបានសរសេរថាតាមរយៈការយាងមករបស់ព្រះគ្រីស្ទនេះ ព្រះ «បានប្រោសឲ្យយើងរួចពីអំណាចនៃសេចក្តី ងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់ យើងរាល់គ្នាមានសេចក្តីប្រោសលោះក្នុងព្រះរាជបុត្រានោះ គឺជាសេចក្តីផ្តាច់បាប» (កូល៉ុស ១:១៣-១៤)។ ទ្រង់នឹងយាងមកជាលើកទីពីរដោយឫទ្ធានុភាពនិងឧត្តមភាពដោយការមើលឃើញដើម្បីរំដោះផែនដីចេញពីបណ្តាសារបស់អំពើបាប ដើម្បីប្រទានសិរីល្អដល់រាស្ត្ររបស់ទ្រង់ និងដើម្បីបង្កើតការគ្រប់គ្រងប្រកបដោយអធិបតីភាពរបស់ទ្រង់ដ៏នៅអស់កល្បជានិច្ចនៅក្នុងសិរីរុងរឿងដ៏គ្រប់លក្ខណ៍របស់ផ្ទៃមេឃថ្មី និងផែនដីថ្មី។

ដូច្នេះ យើងត្រូវតែគិតទាំងពីរ «អាណាចក្រសុចរិត ឬសេចក្តីសង្គ្រោះបច្ចុប្បន្ននេះដែលជាសម័យមនុស្សអាចទទួលយកឬបដិសេធនគរព្រះ និងអំពីអាណាចក្រនាពេលអនាគតនៅពេលឫទ្ធានុភាពរបស់នគរព្រះនឹងត្រូវបានបើកសំដែងនៅក្នុងសិរីល្អដែលមើលឃើញ។ នគរព្រះបច្ចុប្បន្នត្រូវបានចាប់ផ្តើមនៅក្នុងការចាប់ផ្តើមតូចមួយដោយគ្មានការបង្ហាញឲ្យឃើញពីខាងក្រៅ ហើយអស់អ្នកដែលទទួលយកនគរព្រះនេះ នឹងរស់នៅលាយឡំជាមួយអស់អ្នកដែលបដិសេធនគរព្រះរហូតដល់ព្រះគ្រីស្ទយាងមកវិញជាលើកទីពីរ។ ពេលនោះយើងនឹងមើលឃើញនគរព្រះនៅក្នុងការបើកសំដែងដ៏មានអំណាចព្រះចេស្តានិងសិរីល្អ។ នគរព្រះនឹងមកដល់ គឺជាការបំពេញសម្រេចអំពីបំណងព្រះហឫទ័យរបស់ព្រះនៅគ្រប់ទីកន្លែងនិងអស់កល្បជានិច្ច»។[៨]

## *ការរស់ឡើងវិញ*

ការរស់ឡើងវិញរបស់រូបកាយគឺជាសេចក្តីសង្ឃឹមរបស់គ្រីស្ទបរិស័ទដែលយើងជារឿយៗមិនយកចិត្តទុកដាក់ចំពោះការនេះ។ រាស្ត្ររបស់ព្រះនឹងមានរូបកាយរស់ឡើងវិញខាងសាច់ឈាមនិងទទួលបានសិរីល្អដ៏នៅ អស់កល្បជានិច្ច។ នៅក្នុង ១កូរិនថូស ១៥:៥០-៥៧ លោកប៉ុលបានសរសេរ

> បងប្អូនអើយ សេចក្តីដែលខ្ញុំចង់និយាយនេះ គឺថា សាច់ឈាមពុំអាចនឹងគ្រងនគរព្រះ ជាមរដកបានឡើយ ហើយសេចក្តីពុករលួយក៏ពុំអាចនឹងគ្រងសេចក្តីដែលមិនចេះពុករលួយបានដែរ នែ ខ្ញុំប្រាប់អ្នករាល់គ្នាពីសេចក្តីអាថ៌កំបាំង គឺថា យើងទាំងអស់គ្នានឹងមិនដេកលក់ទៅទេ តែទាំងអស់គ្នា នឹងបានផ្លាស់ប្រែកទៅក្នុង ១ រំពេចវិញ គឺក្នុង ១ ប៉ប្រិចភ្នែកប៉ុណ្ណោះ ក្នុងកាលដែលឮសូរត្រែ ក្រោយបង្អស់ ដ្បិតត្រែនឹងឮឡើងមែន នោះពួកស្លាប់នឹងរស់ឡើងវិញមិនពុករលួយទៀតឡើយ រួចយើងរាល់គ្នានឹងបានផ្លាស់ប្រែទៅ ដ្បិតត្រូវតែរូបកាយដ៏ពុករលួយនេះ បានប្រដាប់ដោយសេចក្តីមិនពុករលួយវិញង ហើយរូបកាយដែលរមែងស្លាប់នេះ ត្រូវតែបានប្រដាប់ដោយសេចក្តីមិនចេះស្លាប់វិញដែរ កាលណារូបកាយពុករលួយនេះបានប្រដាប់ដោយសេចក្តីមិនពុករលួយ ហើយរូបកាយដែលតែងតែស្លាប់នេះបានប្រដាប់ដោយសេចក្តី មិនចេះស្លាប់វិញនោះ ទើបនឹងបានសម្រេចតាមពាក្យ ដែលចែងទុកមកថា សេចក្តីជ័យជំនះបានលេបសេចក្តីស្លាប់បាត់ហើយ ឱសេចក្តីស្លាប់អើយ ទ្រនិចឯងនៅឯណា? សេចក្តីស្លាប់អើយ ជ័យជំនះរបស់ឯងនៅឯណា? រីឯទ្រនិចនៃសេចក្តីស្លាប់ គឺជាអំពើបាប ហើយអំណាចរបស់បាប គឺជាក្រិត្យវិន័យ តែអរព្រះគុណដល់ព្រះអង្គ ពីព្រោះទ្រង់ប្រទានឱ្យយើងរាល់គ្នាមានជ័យជំនះ ដោយសារព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង។

ឃ្លាគន្លឹះគឺជាការប្រកាសរបស់ប៉ុលដែលថា «សាច់និងឈាមពុំអាចនឹងគ្រងនគរព្រះជាមរដកបានឡើយ» (ខ. ៥០)។ រូបកាយដែលពុករលួយនិងវិនាសមិនអាចចូលរួមក្នុងនគរព្រះដែលមិនពុករលួយនិងវិនាសបានទេ។ ឬក៏មនុស្សរស់ («សាច់និងឈាម») ឬ មនុស្សស្លាប់ («អ្នកវិនាស) មិនអាចគ្រងនគរព្រះនៅក្នុងសណ្ឋានបច្ចុប្បន្នរបស់ពួកគេបានឡើយ។

ដូច្នេះ ប៉ុលបានសរសេរថា យើងមិនត្រឹមតែត្រូវការការកើតជាថ្មីប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវការការរស់ឡើងវិញ ដែលជាការទទួលបានសិរីល្អរបស់អ្នកជឿហើយវានឹងកើតឡើងនៅពេលព្រះគ្រីស្ទយាងត្រឡប់មកវិញជាលើកទីពីរផងដែរ (ប្រៀបធៀបៈ ១ថែស្សាឡូនិច ៤:១៣-១៨)។ មានតែអស់អ្នកដែលបានផ្លាស់ប្រែក្នុងរូបកាយនិងវិញ្ញាណដោយការរស់ឡើងវិញ/ការទទួលបានសិរីល្អនៅពេលព្រះគ្រីស្ទយាងត្រឡប់មកវិញជាលើកទីពីរប៉ុណ្ណោះដែលនឹងគ្រងនគរព្រះជាមរដក។

២កូរិនថូស ៥:១-៥ គឺជាបទគម្ពីរសំខាន់អំពីការនេះ។ ប៉ុលនិយាយថា ការស្លាប់ខាងឯសាច់ឈាមគឺដូចជាការរើត្រសាល(រោង ឬ ជំរក)ដែលជាទីលំនៅ។ ប៉ុន្តែការស្លាប់មិនគួរនាំទៅដល់ការអស់សង្ឃឹមទេ ពីព្រោះ «យើងមានវិមានមួយពីព្រះនៅអស់កល្បជានិច្ចនៅស្ថានសួគ៌ គឺជាផ្ទះមិនធ្វើដោយដៃមនុស្ស» (ខ. ១)។ មានការកាត់ស្រាយជាច្រើន តែការកាត់ស្រាយល្អបំផុតគឺថា ប៉ុលកំពុងនិយាយអំពីរូបកាយដែលរស់ឡើងវិញនិងទទួលបានសិរីល្អ ដែលជាតំណាងចុងក្រោយនិងគ្រប់លក្ខណ៍ដែលយើងនឹងរស់នៅអស់កល្បជានិច្ច។

ការជំទាស់ធំចំពោះទស្សនៈនេះគឺការដែលប៉ុលប្រើប្រយោគបច្ចុប្បន្នកាល «យើងមានវិមានមួយពីព្រះ» (មិនមែន «យើងនឹងមាន»)នោះទេ។ នេះហាក់ដូចជាកំណត់សេចក្តីថា ភ្លាមៗបន្ទាប់ពីការស្លាប់ ពួកគ្រីស្ទបរិស័ទទទួលបានរូបកាយឧត្តមរបស់ពួកគេ។ ប៉ុន្តែគំនិតនេះផ្ទុយពី១កូរិនថូស ១៥:២២-២៨, ៥១-៥៦, ១ថែស្សាឡូនិច ៤-៥ ហើយប្រហែល ១យ៉ូហាន ៣:១-៣ ដែលបទគម្ពីរទាំងនេះបង្រៀនថា ការទទួលបានសិរីល្អកើតឡើងនៅឯការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ។

លើសពីនេះ ជារឿយៗនៅក្នុងព្រះគម្ពីរ យើងដឹងថា អស់អ្នកនៅក្នុងព្រះគ្រីស្ទនឹងទទួលជីវិតអស់កល្បជានិច្ចនិងគ្រងនគរព្រះជាមរដក*ជាមិនខាន* ដូច្នេះអ្នកនិពន្ធសរសេរអំពីនេះនៅក្នុងប្រយោគបច្ចុប្បន្នកាល ដូចជាវាជារបស់យើងរួចរាល់ទៅហើយ។ ដូច្នេះ ប្រយោគបច្ចុប្បន្នកាលរបស់ប៉ុល «យើងមាន» ទំនងជាចង្អុលទៅកាន់សេចក្តីពិតនៃការមានក៏ដូចជាភាពអចិន្ត្រៃរបស់ការមាន ប៉ុន្តែមិនមែនមានន័យថាយើងមានហើយនោះទេ។ នេះគឺជារបៀបដែលពួកអ្នកនិពន្ធសរសេរអំពីសេចក្តីសង្ឃឹមរបស់យើង។

អ្នកខ្លះនិយាយថា ប្រហែលប៉ុលប្រើប្រយោគបច្ចុប្បន្នកាលដោយព្រោះពួកបរិសុទ្ធនៅស្ថានសួគ៌មិនដឹងឬមានបទពិសោធន៍ជាមួយការកន្លងទៅរបស់ពេលវេលារវាងការស្លាប់ខាងឯសាច់ឈាមនិងការរស់ឡើងវិញនៅចុងក្រោយទេ ដូច្នេះហើយ ហាក់ដូចជាការទទួលបានរូបកាយរស់ឡើងវិញរបស់មនុស្សមានភ្លាមៗបន្ទាប់ពីការស្លាប់។ ប៉ុន្តែគំនិតនេះប្រឆាំងនឹងសេចក្តីបង្រៀនច្បាស់លាស់របស់ព្រះគម្ពីរដែលថា អស់អ្នកដែលបានស្លាប់ហើយទៅស្ថានសួគ៌ឥឡូវនេះបានដឹងខ្លួន (សូមមើល២កូរិនថូស ៥:៦-៨; ភីលីព ១:២១-២៤; វិវរណៈ ៦:៩-១១)។ បើសិនគ្រីស្ទបរិស័ទម្នាក់ដែលស្លាប់បាន «ចាកចេញ» ទៅនៅ «ជាមួយព្រះគ្រីស្ទ» (ភីលីព ១:២៣) ហើយនៅ «ជាមួយ» ព្រះគ្រីស្ទនៅពេលទ្រង់យាងមក (១ថែស្សាឡូនិច ៤:១៧) នេះហាក់ដូចជាទូទៅ អំពីប្រភេទនៃការដឹងខ្លួនរវាងការស្លាប់របស់មនុស្សម្នាក់ និងការរស់ឡើងវិញ។

ប៉ុលមានសេចក្តីសង្ឃឹមថា បន្ទាប់ពីគាត់ស្លាប់ខាងសាច់ឈាម គាត់នឹងនៅតែនៅរស់រហូតដល់ព្រះគ្រីស្ទយាងត្រឡប់មកវិញ។ ដូច្នេះ គាត់សរសេរថាៈ

> ដ្បិតនៅក្នុងត្រសាលនេះ យើងខ្ញុំតែងតែថ្ងូរ ដោយសង្វាតនឹងចង់ប្រដាប់ខ្លួន ដោយទីលំនៅរបស់យើងខ្ញុំ ជាទីលំនៅដែលមកពីស្ថានសួគ៌ណាស់ ឱ្យតែយើងខ្ញុំបានប្រដាប់ខ្លួនចុះ ដើម្បីកុំឱ្យមានឃើញយើងខ្ញុំនៅអាក្រាតឡើយ ដ្បិតយើងខ្ញុំដែលនៅក្នុងត្រសាលនេះ យើងថ្ងូរមែនដោយមានបន្ទុកយ៉ាងធ្ងន់ ពីព្រោះយើងមិនចង់ដោះ

សំលៀកបំពាក់នេះចេញទេ គឺចង់តែស្លៀកពាក់វិញដើម្បីឱ្យជីវិតបានលេបរបស់ ដែលតែងតែស្លាប់ឱ្យបាត់ទៅនោះ រីឯអ្នកដែលបានបង្កើតយើងខ្ញុំសម្រាប់ការនោះឯងជាព្រះដែលទ្រង់ក៏ប្រទានព្រះវិញ្ញាណ មកបញ្ចាំចិត្តយើងខ្ញុំដែរ។ (២កូរិនថូស ៥:២-៥)។

ទីនេះប៉ុលសរសេរអំពីបំណងចិត្តរបស់គាត់ចង់នៅរស់ពេលព្រះគ្រីស្ទយាងត្រឡប់មកវិញ ពីព្រោះគាត់នឹងមិនចាំបាច់ស្លាប់ខាងឯសាច់ឈាមនិងមានបទពិសោធន៍ការដាច់រូបកាយចេញពីវិញ្ញាណ ដែលជាលក្ខខណ្ឌមួយដែលគាត់ហៅថា « នៅអាក្រាត» (ខ. ៣) ឬ «ដោះសំលៀកបំពាក់» (ខ. ៤)។ គាត់ចង់រួមរស់ភ្លាមៗជាមួយព្រះអម្ចាស់នៅក្នុងរូបកាយឧត្តមនិងរស់ឡើងវិញរបស់គាត់។

នៅក្នុង២កូរិនថូស ៥:២ ដែលខ. ៤ និយាយឡើងវិញនិងពង្រីកបន្ថែម លោកប៉ុលសរសេរអំពីការប្រដាប់ខ្លួន ឬយកទីលំនៅសំរាប់ស្លៀកពាក់។ ប៉ុន្តែនេះលើសជាងស្លៀកសំលៀកបំពាក់ទៅទៀតៈ នេះគឺជាការស្លៀកសំលៀកបំពាក់មួយត្រួតលើសំលៀកបំពាក់មួយទៀត។ រូបកាយនៅស្ថានសួគ៌ ដូចជាអាវធំមួយ ត្រូវបានស្លៀកត្រួតលើរូបកាយនៅផែនដីដែលសាវ័កប៉ុលបានសរសេរអំពី។ នៅក្នុងរបៀបនេះ រូបកាយឧត្តមនៅស្ថានសួគ៌មិនគ្រាន់តែជាអាវក្រៅនោះទេ ប៉ុន្តែវាក៏ផ្លាស់ប្រែរូបកាយនៅផែនដីផងដែរ (សូមមើលភីលីព ៣:២០-២១; ១កូរិនថូស ១៥:៥៣)។

បើសិនគាត់ (ឬយើង) នៅរស់រហូតដល់ព្រះគ្រីស្ទយាងត្រឡប់មកវិញ នោះព្រះអម្ចាស់នឹងមើលឃើញថា គាត់ប្រដាប់ដោយរូបកាយមួយ (រូបកាយនៅផែនដីបច្ចុប្បន្ន) ហើយមិនមែនដោយសណ្ឋានដាច់ចេញពីរូបកាយ។ បើសិនគ្មានរូបកាយនោះទេ នោះយើងត្រូវតែ «អាក្រាត» (២កូរិនថូស ៥:៣)។ ប៉ុលជឿលើសណ្ឋានដាច់ចេញពីរូបកាយរវាងសេចក្តីស្លាប់ខាងសាច់ឈាមនិងការរស់ឡើងវិញជាទូទៅ (ប្រៀបធៀបៈ «ដោះសំលៀកបំពាក់ចេញ » នៅក្នុងខ. ៤)។

ប៉ុន្តែតើយើងបានការធានាអ្វីពីព្រះដែលថា ទ្រង់នឹងប្រទានរូបកាយឧត្តមអស់កល្បជានិច្ចដែលនឹងលែងយ៉ាប់យ៉ឺនឬមានជម្ងឺទៀតនោះ? ចំលើយសាមញ្ញគឺថា ព្រះវិញ្ញាណបរិសុទ្ធ! ការថ្លែងរបស់ប៉ុលនៅក្នុង២កូរិនថូស ៥:៥ គឺជាការរំលឹកមួយ «ថា..ព្រះ វិញ្ញាណបរិសុទ្ធនៅក្នុងអ្នកជឿ ធានាគាត់ថា អំណាចដដែលដែលបានប្រោសព្រះគ្រីស្ទយេស៊ូវពីសុគតក៏មានវត្តមាននិងធ្វើការនៅក្នុងគាត់ផងដែរ ដើម្បីរៀបចំរូបកាយពុករលួយរបស់គាត់សំរាប់ការធ្វើឲ្យគ្រប់លក្ខណ៍ជាចុងក្រោយនៃសេចក្តីប្រោសលោះរបស់ទ្រង់នៅក្នុងការប្រទានសិរីល្អដល់រូបកាយរបស់គាត់»។[10]

ដូច្នេះ ពួកគ្រីស្ទបរិស័ទមិនគួរខ្លាចសេចក្តីស្លាប់ឡើយ។ យើងដឹងថា ទោះឥឡូវនេះយើងមានជម្ងឺអ្វីក៏ដោយ ប្រឈមនឹងការរងទុក្ខឬទុក្ខលំបាកអ្វីក៏ដោយ ក៏ព្រះ វិញ្ញាណសន្យានឹងប្រទានទីលំនៅដែលមានសិរីល្អនិងបានផ្លាស់ប្រែដូចជាព្រះគ្រីស្ទអស់កល្បជានិច្ច គឺជារូបកាយដែលគ្មានជម្ងឺ គ្មានការឈឺចាប់ គ្មានការខ្វះខាត និងគ្មានសេចក្តីពុករលួយ។ ប៉ុលហាក់ដូចជានិយាយថា ឆុតឆាកល្អបំផុតគឺត្រូវនៅរស់នៅពេលព្រះគ្រីស្ទយាងត្រឡប់មកវិញ។ តាមរបៀបនេះ អ្នកជឿនឹងផ្លាស់ប្តូរភ្លាមៗពី «សំលៀកបំពាក់» នេះ (រូបកាយខាងសាច់ឈាមបច្ចុប្បន្នរបស់យើង) ទៅជា «ប្រដាប់តែងកាយ» ឧត្តម ( ដែលជារូបកាយរស់ឡើងវិញរបស់យើងអស់កល្បជានិច្ច)។ ប៉ុលមិនចង់នៅ «អាក្រាត» ទេ ប៉ុន្តែគាត់ចង់ស្លៀកសំលៀកបំពាក់អស់កល្បជានិច្ចត្រួតលើសំលៀកបំពាក់ពុករលួយនៅក្នុងរបៀបដែលសំលៀកបំពាក់ក្រៅប្រោសលោះនិងផ្លាស់ប្រែសំលៀកបំពាក់ក្នុងវិញ។

សាវ័កប៉ុលក៏ប្រយ័ត្នប្រយែងភ្ជាប់ការរស់ឡើងវិញនិងការទទួលសិរីល្អចុងក្រោយរបស់ពួកអ្នកជឿទៅនឹងការត្រឡប់បណ្តាសាដែលមានលើរបស់សព្វសារពើៈ

ខ្ញុំរាប់អស់ទាំងសេចក្តីទុក្ខលំបាកនៅជាន់នេះ ថាជាសេចក្តីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អដែលនឹងបើកសំដែងមកឱ្យយើងរាល់គ្នាឃើញនោះទេ ដ្បិតសេចក្តីទន្ទឹងរបស់ជីវិតទាំងឡាយ នោះរង់ចាំតែពួកកូនរបស់ព្រះលេចមកឱ្យឃើញប៉ុណ្ណោះទេ ពីព្រោះជីវិតទាំងឡាយ បានត្រូវចុះចូលនឹងសេចក្តីឥតប្រយោជន៍ តែមិនមែនដោយស្ម័គ្រពីចិត្ត គឺដោយព្រោះព្រះអង្គដែលទ្រង់បញ្ចុះបញ្ចូលវិញដោយសង្ឃឹមថា ជីវិតទាំងនោះឯង នឹងបានរួចពី ចំណងនៃសេចក្តី

ពុករលួយ ឱ្យបានសេរីភាពនៃសិរីល្អ របស់ពួកកូនព្រះវិញ ដ្បិតយើងដឹងថា ជីវិតទាំងឡាយ ក៏ថ្ងូរ ហើយឈឺចាប់ជាមួយគ្នា ដរាបដល់គ្រាឥឡូវនេះ មិនតែប៉ុណ្ណោះសោត ខ្លួនយើងរាល់គ្នាដែលមានផលជាដំបូងរបស់ព្រះវិញ្ញាណ ក៏ថ្ងូរក្នុងខ្លួនដែរ ទាំងរង់ចាំ ទំរាំការទទួលជាកូនចិញ្ចឹម គឺជាសេចក្តីប្រោសលោះដល់ រូបកាយយើងផង (រ៉ូម ៨:១៨-២៣)។

ការសង្គ្រោះរបស់សព្វសារពើមានទំនាក់ទំនងដែលមិនអាចបំបែកបានជាមួយការសង្គ្រោះពួកកូនរបស់ព្រះ។ របស់សព្វសារពើនឹងត្រូវប្រោសលោះនៅពេលពួកកូនរបស់ព្រះត្រូវបើកសំដែង (រ៉ូម ៨:១៩)។ នេះជាមូលហេតុដែលរបស់សព្វសារពើកំពុង «រង់ចាំតែពួកកូនរបស់ព្រះលេចមកឱ្យឃើញ»។

របស់សព្វសារពើរង់ចាំការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទនិងការទទួលបានសិរីល្អរបស់យើង ពីព្រោះរបស់សព្វសារពើក៏នឹងត្រូវដោះឲ្យមានសេរីភាពពី «ចំណងនៃសេចក្តីពុករលួយ» ទៅក្នុង «សេរីភាពនៃសិរីល្អរបស់ពួកកូនព្រះផងដែរ»(ខ. ២១)។ របស់សព្វសារពើរង់ចាំការបើកសំដែងពួកកូនរបស់ព្រះ (ខ. ១៩) ពីព្រោះរបស់សព្វសារពើក៏នឹងត្រូវបានរំដោះចេញទៅក្នុងសេរីភាពផងដែរ (ខ. ២១)។ របស់សព្វសារពើនិងពួកកូនរបស់ព្រះមូលផ្តុំគ្នាទាំងក្នុងការរងទុក្ខបច្ចុប្បន្ន និងក្នុងសិរីល្អនាពេលអនាគត។ ដោយព្រោះរាស្ត្ររបស់ព្រះនិងរបស់សព្វសារពើពាក់ព័ន្ធគ្នានៅក្នុងការធ្លាក់ចុះ នោះរាស្ត្ររបស់ព្រះនិងរបស់សព្វសារពើក៏នឹងពាក់ព័ន្ធគ្នានៅក្នុងការស្តារឡើងវិញផងដែរ។

សេចក្តីប្រោសលោះដែលយើងនឹងមាននៅពេលព្រះគ្រីស្ទយាងត្រឡប់មកវិញ គឺជាការបំផ្លាញអំពើបាបចោលជាចុងក្រោយនិងចប់សព្វគ្រប់ និងការបំផ្លាញអស់ទាំងសេចក្តីពុករលួយនៅក្នុងវិញ្ញាណនិងសាច់ឈាមរបស់យើងនៅមុនការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទ។ គំនិតរបស់ប៉ុលគឺថា របស់សព្វសារពើរង់ចាំថ្ងៃនោះ ពីព្រោះព្រះអង្គនឹងប្រោសលោះ និងសង្គ្រោះរបស់សព្វសារពើយ៉ាងពេញលេញនាថ្ងៃនោះ។ បើសិនរបស់សព្វសារពើមិនត្រូវបានសង្គ្រោះទាំងស្រុងចេញពីសេចក្តីពុករលួយបច្ចុប្បន្ននេះទេ នោះចុងបញ្ចប់នៃភាពពេញលេញនៃសេចក្តីប្រោសលោះរបស់យើងនឹងត្រូវចុះខ្សោយហើយ។ បើសិនរបស់សព្វសារពើមិនត្រូវបានប្រោសលោះទាំងស្រុងនិងឥតខ្ចោះនោះទេ នោះយើងក៏នឹងមិនត្រូវបានប្រោសលោះទាំងស្រុងនិងឥតខ្ចោះផងដែរ។ ដូច្នេះ របស់សព្វសារពើត្រូវបានប្រោសលោះយ៉ាងឥតខ្ចោះដូចជាយើង ហើយក្នុងពេលតែមួយដូចជាយើងផងដែរ។

## *ការវិនិច្ឆ័យ*

២កូរិនថូស ៥ បង្រៀនថា នឹងមានការវិនិច្ឆ័យចុងក្រោយជាមិនខាន។ លោកប៉ុលបង្រៀនថា «ហេតុនោះបានជាយើងខ្ញុំសង្វាត ឱ្យបានគាប់ដល់ព្រះហឫទ័យទ្រង់ ទោះនៅក្នុងរូបកាយ ឬឃ្លាតពីរូបកាយក្តី ដ្បិតយើងទាំងអស់គ្នាត្រូវទៅនៅមុខទីជំនុំជំរះរបស់ព្រះគ្រីស្ទ ដើម្បីឱ្យគ្រប់គ្នាបានទទួលតាមការដែលបានធ្វើ ពីកាលនៅក្នុងរូបកាយរៀងខ្លួន ទោះល្អឬអាក្រក់ក្តី» (២កូរិនថូស ៥:៩-១០)។

បរិបទរបស់២កូរិនថូស ៤-៥ បង្ហាញថា នៅក្នុងបទគម្ពីរនេះ ប៉ុលកំពុងនិយាយអំពីពួកអ្នកជឿតែប៉ុណ្ណោះ។ លោកហារីស មឺរេ Harris Murray បានបង្ហាញថា នៅពេលណាប៉ុលសរសេរអំពីការវិនិច្ឆ័យតាមការប្រព្រឹត្តរបស់មនុស្សទាំងអស់ (ដូចជាក្នុងរ៉ូម ២:៦) «នោះមានការពិពណ៌នាអំពីមនុស្សពីរក្រុម (រ៉ូម ២:៧-១០) មិនមែនសកម្មភាពពីរប្រភេទ[ដូចជា 'ល្អឬអាក្រក់'នៅក្នុង២កូរិនថូស ៥:១០] ដែលមនុស្សទាំងអស់ធ្វើនោះទេ»។[11]

នៅទីនេះលោកប៉ុលមិនសរសេរអំពីការវិនិច្ឆ័យដែលដែលមនុស្សទាំងអស់នឹងទទួលនោះទេ ប៉ុន្តែប៉ុលសរសេរអំពីការវិនិច្ឆ័យដែលវាយតំលៃលើជីវិតរបស់រាស្ត្ររបស់ព្រះដើម្បីកំណត់ថា យើងនឹងទទួលរង្វាន់យ៉ាងធំឬយ៉ាងតូច (យ៉ូហាន ៣:១៨, ៥:២៤ រ៉ូម ៥:៨-៩, ៨:១, ១ថែស្សាឡូនិច ១:១០)។ ការវិនិច្ឆ័យនេះមិនមែនដើម្បីកំណត់ថាអ្នកណានឹងចូលទៅក្នុងនគរព្រះនោះទេ ប៉ុន្តែកំណត់ព្រះពរ ឋានៈ និងអំណាចដែលយើងនឹងបាននៅក្នុងស្ថានសួគ៌។ ប៉ុលដឹងមិនច្បាស់ថា

ពេលណាដែលការវិនិច្ឆ័យនេះកើតឡើងទេ។ តើការវិនិច្ឆ័យនោះកើតឡើងនៅពេលដែលយើងស្លាប់ខាងឯសាច់ឈាម ឬប្រហែលក្នុងអំឡុងសណ្ឋានកណ្តាល ឬចាំរហូតដល់ព្រះគ្រីស្ទយាងមកជាលើកទីពីរ? អ្វីដែលយើងអាចមានភាពច្បាស់លាស់បំផុតគឺថា ការវិនិច្ឆ័យនោះនឹងកើតឡើងបន្ទាប់ពីយើងស្លាប់ (សូមមើលហេព្រើរ ៩:២៧)។

ការវិនិច្ឆ័យនេះប្រហែលកើតឡើងនៅឯការយាងត្រឡប់មកជាលើកទីពីររបស់ព្រះគ្រីស្ទ (សូមមើលម៉ាថាយ ១៦:២៧; វិវរណៈ ២២:១២) នៅឯទីអវសានកាលនៃពិភពលោក ដែលទំនងជាមានទាំងការវិនិច្ឆ័យដែលនឹងរួមបញ្ចូលទាំងពួកអ្នកមិនជឿទាំងអស់ផង។ នេះគឺជាបាល័ង្កវិនិច្ឆ័យពណ៌សមួយយ៉ាងធំ (សូមមើលវិវរណៈ ២០:១១...)។

ប៉ុលសង្កត់ធ្ងន់យ៉ាងច្បាស់ថា មនុស្សម្នាក់ៗនឹងត្រូវបានវិនិច្ឆ័យ។ ថ្វីបើវាជាការសំខាន់ក្នុងការសង្កត់ធ្ងន់ថា ពួកគ្រីស្ទបរិស័ទរស់នៅជាផ្នែកនៃសហគមន៍មួយដែលជារូបកាយរបស់ព្រះគ្រីស្ទ ក៏មនុស្សម្នាក់ៗនឹងត្រូវបានវិនិច្ឆ័យរៀងៗខ្លួន។ ច្បាស់ណាស់ថា ការមួយដែលព្រះនឹងវិនិច្ឆ័យគឺ ភាពស្មោះត្រង់ប៉ុណ្ណាដែលគ្រីស្ទបរិស័ទមាននៅក្នុងទំនួលខុសត្រូវរបស់គាត់ចំពោះសហគមន៍។ «ដូច្នេះ យើងទាំងអស់គ្នានឹងត្រូវរាប់រៀបទូលថ្វាយព្រះពីដំណើររបស់ខ្លួនយើងជាមិនខាន» (រ៉ូម ១៤:១២។

នៅពេលវិនិច្ឆ័យយើងនឹងនៅជាអាក្រាតនៅចំពោះទ្រង់។ ដូចប៉ុលបាននិយាយនៅក្នុង១កូរិនថូស ៤:៥ ថា ព្រះអម្ចាស់ «នឹងយកអស់ទាំងអំពើលាក់កំបាំងដែលធ្វើនៅទីងងឹតមកដាក់នៅទីភ្លឺវិញ ហើយនឹងបើកសំដែងឲ្យឃើញអស់ទាំងគំនិតក្នុងចិត្តរបស់មនុស្សផង»។ លោក មីរេ ហារីស និយាយបានត្រឹមត្រូវថា «ការបើកសំដែងអំពីជីវិតរបស់យើងនិងការពិនិត្យមើលគំនិតនិងការប្រព្រឹត្តរបស់យើង គឺចាំបាច់សម្រាប់ការដែលយើងទទួលបានសំណងដែលសមរម្យ»។[១២]

ការដឹងថាគ្រប់ទាំងគំនិតព្រាវៗ គ្រប់ទាំងការជំរុញចិត្តសុចរិត គ្រប់ទាំងសេចក្តីអធិស្ឋានអាថ៌កំបាំង ទង្វើរលាក់កំបាំងអំពើដែលយើងភ្លេចជាយូរមកហើយ ឬសកម្មភាពមេត្តាករុណា នឹងត្រូវបានលាតត្រដាងចំពោះមុខយើងដើម្បីទទួលស្គាល់និងសម្រាប់ព្រះវិនិច្ឆ័យធ្វើឲ្យយើងគិតយ៉ាងប្រយ័ត្នប្រយែងអំពីជិវិតរបស់យើង។ ហើយការបើកសំដែងទាំងនេះនឹងកើតឡើងដោយគ្មានអ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ត្រូវជាប់មានទោសសោះ (រ៉ូម ៨:១)។

ពួកគ្រីស្ទបរិស័ទភាគច្រើនស្គាល់ពាក្យដែលបានប្រើនៅក្នុង២កូរិនថូស ៥:១០ បានបកប្រែការវិនិច្ឆ័យគឺជា «ទីជំនុំជំរះ» (bema)។ ការប្រើពាក្យនេះ «នឹងជាការរំឭកដល់ប៉ុលនិងពួកកូរិនថូស ពីព្រោះប៉ុលបានមានរឿងក្តីជាមួយកាលីយ៉ូរយៈពេលបួនឆ្នាំមុន (ក្នុងឆ្នាំ៥២គ.ស) នៅក្នុងក្រុងកូរិនថូសដែលជាកន្លែងអ្នកតំណាងជាតិរ៉ូមបានលើកលែងការចោទប្រកាន់ដែលថា ប៉ុលបានរំលោភច្បាប់របស់រ៉ូម៉ាំង (កិច្ចការ ១៨:១២-១៧)។ អ្នកបុរាណវត្ថុវិទ្យាបានរកឃើញទីជំនុំជំរះ (bema) របស់ពួកកូរិនថូស»។[១៣]

ព្រះគ្រីស្ទគឺជាចៅក្រម នៅក្នុងយ៉ូហាន ៥:២២ ទ្រង់បានប្រកាសថា «ព្រះវរបិតាទ្រង់មិនជំនុំជំរះអ្នកណាទេ ទ្រង់បានប្រគល់ការជំនុំជំរះដល់ព្រះរាជបុត្រាវិញ»។ ខ្នាតគំរូនៃការវិនិច្ឆ័យគឺ «អ្វីដែលមនុស្សបានធ្វើនៅក្នុងរូបកាយ មិនថាល្អឬអាក្រក់»។ ការលើកឡើងពី «រូបកាយ» បង្ហាញថា ការវិនិច្ឆ័យទាក់ទងនឹងអ្វីដែលយើងធ្វើនៅក្នុងជីវិត មិនមែនបន្ទាប់ពីយើងស្លាប់នោះទេ ប៉ុន្តែនៅមុនព្រះគ្រីស្ទយាងត្រឡប់មកវិញម្តងទៀត។

និយាយតាមពាក្យផ្សេង ព្រះនឹងវិនិច្ឆ័យយើង «តាម» ឬប្រហែល «ឲ្យសមនឹង» ទង្វើរដែលយើងបានប្រព្រឹត្ត។ ទង្វើរទាំងអស់អាចជា «ល្អ» (ទង្វើរទាំងអស់ដែល «ផ្គាប់ដល់»ព្រះគ្រីស្ទ ដូចនៅក្នុង២កូរិនថូស ៥:៩) ឬអាចជា «អាក្រក់» (ទង្វើរទាំងអស់ដែលមិនផ្គាប់ដល់ព្រះគ្រីស្ទ)។

ទីបំផុត លទ្ធផលនៃការវិនិច្ឆ័យមិនត្រូវបានថ្លែងនោះទេ ប៉ុន្តែនឹងត្រូវបានបញ្ជាក់ជាការពិត។ គ្រប់គ្នានឹង «ទទួលបាន» អ្វីដែលទង្វើររបស់ពួកគេសមនឹងទទួលបាន។ យើងនឹងទទួលរង្វាន់ឬសំណង។ ប៉ុលបញ្ជាក់ច្បាស់ជាងនេះបន្តិចនៅក្នុង ១កូរិនថូស ៣:១៤-១៥។ នៅទីនោះគាត់បានសរសេរថា:«បើការដែលអ្នកណាសង់ឡើង បានជាប់នៅ អ្នកនោះនឹងបានរង្វាន់ បើការដែល អ្នកណា ធ្វើត្រូវឆេះ អ្នកនេះនឹងត្រូវខាតវិញ តែខ្លួនអ្នកនោះនឹង បានរួចបែបដូចជាដើរកាត់ភ្លើង។»។

ប៉ុលមិនពន្យល់ថា រង្វាន់នោះគឺជាអ្វី ហើយអ្វីដែលអ្នកនោះនឹងត្រូវខាតគឺជាអ្វីនោះទេ។ប្រហែលជាគាត់ខាតរង្វាន់ដែលនឹងត្រូវប្រទានអស់អ្នកដែលស្ដាប់បង្គាប់ព្រះ។

ព្រះយេស៊ូវមានបន្ទូលអំពីរង្វាន់ដ៏ធំមួយនៅក្នុងស្ថានសួគ៌ ប៉ុន្ដែមិនពន្យល់បន្ថែមថា រង្វាន់នោះគឺជាអ្វីនោះទេ (ម៉ាថាយ ៥:១២)។ ក្នុងរឿងប្រៀបប្រដូចអំពីការប្រគល់ប្រាក់(ម៉ាថាយ ២៥ ប្រៀបធៀបៈ លូកា ១៩:១២-១៧) ទ្រង់មានបន្ទូលមកកាន់យើងអំពីការមានអំណាចឬអំណាចគ្រប់គ្រង ប៉ុន្ដែអំណាចគ្រប់គ្រងលើអ្នកណាឬលើអ្វី ? លោកប៉ុលសរសេរថា «ដោយដឹងថា ការល្អអ្វីដែលគ្រប់គ្នាធ្វើ នោះនឹងបានរង្វាន់ពីព្រះអម្ចាស់ ទោះបើជាបាវបម្រើ ឬអ្នកជាក្ដី» (អេភេសូរ ៦:៨)។ យោងតាម១កូរិនថូស ៤:៥ បន្ទាប់ពីការវិនិច្ឆ័យ «គ្រប់គ្នានឹងទទួលបានសេចក្ដីសរសើរពីព្រះអម្ចាស់រៀងៗខ្លួន»។ ទាំងរ៉ូម ៨:១៧-១៨ និង២កូរិនថូស ៤:១៧ សំដៅទៅលើសិរីល្អដែលត្រៀមសម្រាប់ពួកបរិសុទ្ធនៅក្នុងស្ថានសួគ៌។

ហើយយើងគួរតែគិតពិចារណាអំពីសេចក្ដីសន្យាផ្សេងៗនៅក្នុងសំបុត្រទាំងប្រាំពីរទៅកាន់ពួកជំនុំផ្សេងៗនៅក្នុងវិវរណៈ ២-៣ ទោះបើយើងពិបាកដឹងថា សេចក្ដីសន្យាទាំងនេះត្រូវបានប្រទានឲ្យឥឡូវនេះឬអត់ រវាងសេចក្ដីស្លាប់និងការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ ឬបន្ទាប់ពីការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទតែប៉ុណ្ណោះ ហើយអ្នកខ្លះទទួលបានច្រើនជាងនិងអ្នកខ្លះទទួលបានតិចជាងទៅតាមការបម្រើនិងការស្ដាប់បង្គាប់ ឬពួកកូនរបស់ព្រះទទួលបានសេចក្ដីសន្យាទាំងនោះស្មើៗគ្នា(សូមមើលវិវរណៈ ២:៧, ១០, ១៧, ២៣, ៣:៥, ១២, ២១ ប្រៀបធៀបផងដែរ ម៉ាថាយ ១៨:៤, ១៩:២៩; លូកា ១៤:១១; យ៉ាកុប ១:១២)។

អត្ថាធិប្បាយបញ្ចប់ពីរ។ ទីមួយ យើងមិនបានសង្គ្រោះដោយសារទង្វើល្អរបស់យើងនោះទេ ប៉ុន្ដែទង្វើល្អរបស់យើងបង្ហាញថា យើងបានសង្គ្រោះ។ ទង្វើល្អមិនមែនជាឫសរបស់សេចក្ដីសង្គ្រោះរបស់យើងទេ ប៉ុន្ដែជាផលផ្លែវិញ គឺយើងបានរាប់ជាសុចរិតដោយសេចក្ដីជំនឿក្នុងព្រះគ្រីស្ទតែមួយគត់។ ទង្វើល្អដែលនឹងត្រូវបើកសំដែងនៅឯបាល័ង្កវិនិច្ឆ័យរបស់ព្រះគ្រីស្ទ គឺជាភស្ដុតាងដែលមើលឃើញនៃសេចក្ដីជំនឿដែលមើលមិនឃើញ។

ទីពីរ យើងមិនត្រូវខ្លាចថា ការលាតត្រដាងនិងការវាយតំលៃលើការប្រព្រឹត្តរបស់យើងនឹងបណ្ដាលឲ្យមានការស្ដាយក្រោយនិងវិប្បដិសារីដែលបង្ខូចភាពក្សេមក្សាន្តរបស់ស្ថានសួគ៌នោះឡើយ។ បើសិននឹងមានទឹកភ្នែកនៃសេចក្ដីទុក្ខព្រួយដោយសារយើងបានខ្ជះខ្ជាយឱកាសបម្រើព្រះអង្គ ឬទឹកភ្នែកនៃភាពអាម៉ាស់ដោយសារយើងបានធ្វើបាប នោះព្រះអម្ចាស់នឹងជូតពួកវាចេញ (វិវរណៈ ២០:៤ក)។ អំណរដែលមកពីព្រះគុណដែលអត់ទោសនឹងដោះអស់ទាំងទុក្ខព្រួយចេញ ហើយសោភ័ណ្ឌភាពរបស់ព្រះគ្រីស្ទនឹងធ្វើឲ្យយើងមើលមិនឃើញការគ្រប់យ៉ាង ប៉ុន្ដែឃើញតែសិរីរុងរឿងរបស់ទ្រង់ និងអ្វីដែលទ្រង់សម្រេចបានជំនួសយើងដោយសារព្រះគុណប៉ុណ្ណោះ។

## *ស្ថាននរក និងការដាក់ទណ្ឌកម្មអស់កល្បជានិច្ច*

ប្រហែលវិវរណៈ ១៤ មានការបរិយាយច្បាស់លាស់បំផុតអំពីស្ថាននរកនិងការដាក់ទណ្ឌកម្មអស់កល្បជានិច្ច។

> រួចមានទេវតាទី៣ មកតាមក្រោយទៀត ទាំងបន្លឺដោយសំឡេងយ៉ាងខ្លាំងថា បើអ្នកណាក្រាបថ្វាយបង្គំដល់សត្វនោះ និងរូបវា ហើយទទួលទីសំគាល់វានៅលើថ្ងាស ឬនៅដៃ អ្នកនោះនឹងត្រូវផឹកស្រាផងសេចក្តីឃោរឃៅរបស់ព្រះជាស្រាឥតលាយ ដែលចាក់ទៅក្នុងពែងនៃសេចក្តីក្រោធរបស់ទ្រង់ ព្រមទាំងត្រូវរងទុក្ខវេទនា នៅក្នុងភ្លើង និងស្ពាន់ធ័រ ចំពោះមុខនៃពួកទេវតាបរិសុទ្ធ និងកូនចៀមផង ឯផ្សែងនៃសេចក្តីទុក្ខលំបាករបស់គេ និងហុយឡើងអស់កល្បជានិច្ចរៀងរាបតទៅ គេនឹងឥតមានសេចក្តីស្រាកស្រាន្តឡើយ ទាំងយប់ទាំងថ្ងៃ គឺពួកអ្នកដែលក្រាបថ្វាយបង្គំដល់សត្វនោះ និងរូបវា ឬអ្នកណាដែលទទួលទីសំគាល់នៃឈ្មោះវាផង (វិវរណៈ ១៤:៩-១១)។

ឥឡូវនេះមានការពិភាក្សាផ្សេងៗអំពីស្ថាននរក។ តើទារុណកម្មរបស់ពួកអ្នកបាត់បង់គឺជាបទពិសោធន៍ដែលដឹងខ្លួនជារៀងរហូតឬ? ឬតើព្រលឹងរបស់ពួកគេឈប់មាននៅបន្ទាប់ពីពេលវេលារងទុក្ខមួយនៅក្នុងទំហំសមនឹងអំពើបាបដែល

ពួកគេបានប្រព្រឹត្តឬ? តើផ្សែងភ្លើងដែលធ្វើអោយគេរងទុក្ខទោស ហុយអស់កល្បជាអង្វែងតរៀងទៅនេះមានន័យថា ពួកគេមានបទពិសោធន៍នៃការរងទុក្ខដែលដឹងខ្លួនរៀងរហូតឬ? ឬតើផ្សែងដែលហុយឡើងជាសញ្ញានៃលទ្ធផលដែលមិនអាចត្រឡប់ក្រោយបានអស់កល្បជានិច្ចនៃការដាក់ទណ្ឌកម្មរបស់ពួកគេដែលព្រលឹងរបស់ពួកគេឈប់មាននៅឬ?យើងត្រូវមើលអត្ថបទផ្សេងៗទៀតដើម្បីសម្រេចចិត្តថា មនុស្សដែលទទួលទណ្ឌកម្មនៅស្ថាននរកនឹងស្ថិតស្ថេរនៅទីនោះជារៀងរហូតឬទេ។[១៤]

យើងមិនមានកន្លែងទំនេរគ្រប់គ្រាន់ដើម្បីពិភាក្សាអំពីការពិភាក្សារបស់ភាគីទាំងសង្ខាងនោះទេ ប៉ុន្តែមានភស្តុតាងជាច្រើននៅក្នុងព្រះគម្ពីរដែលគាំទ្រអំពីការអះអាងបញ្ជាក់របស់សេចក្តីថ្លែងការណ៍អំពីសេចក្តីជំនឿទៅលើការដាក់ទណ្ឌកម្មដែលដឹងខ្លួនអស់កល្បជានិច្ច។ ជាឧទាហរណ៍ក្រុមពាក្យដែលរួមបញ្ចូល «បំផ្លាញ» និងសទិសន័យ(វេវចនៈសព្ទ)របស់វាត្រូវបានប្រើក្នុងរបៀបផ្សេងៗ ហើយរបៀបខ្លះមិនមានន័យជាការបញ្ឈប់ការបិតនៅនោះទេ។ ពាក្យនេះអាចបរិយាយអំពីអ្វីមួយដែលត្រូវបានបំផ្លាញ ប៉ុន្តែវាបន្តមាននៅហើយមុនពេលយើងសន្និដ្ឋានថា «ភ្លើង» របស់ស្ថាននរកឆេះនិង «បំផ្លាញ» មនុស្សនៅទីនោះអស់រលីងមិនសល់អ្វី នៅក្នុងស្ថាននរក នោះយើងត្រូវតែទទួលស្គាល់ថា នេះគឺជាពាក្យប្រៀបធៀប ដូច្នេះយើងមិនអាចប្រើពាក្យដូច «ភ្លើង» ដើម្បីបង្រៀនអំពីពេលវេលារបស់ស្ថាននរក ពីព្រោះពាក្យទាំងនោះមិនមានគោលបំណងបង្រៀនអំពីរយៈវេលារបស់ស្ថាននរកនោះទេ។

ព្រះគម្ពីរសញ្ញាថ្មីបរិយាយអំពីស្ថាននរកជាសេចក្តីងងឹតទាំងស្រុង និងជាបឹងភ្លើង។ បើសិនយើងកាត់ស្រាយរូបភាពទាំងពីរនេះតាមន័យត្រង់ តើរូបភាពទាំងពីរនេះអាចពិតយ៉ាងដូចម្តេចទៅ? ដូច្នេះ យើងត្រូវតែប្រយ័ត្នប្រយែងក្នុងការទាញជាសេចក្តីសន្និដ្ឋានអំពី «តួនាទី» របស់បឹងភ្លើង។ ប៉ុន្តែលោក ខាសិន សរសេរអំពីម៉ាថាយ ១៨:៨ ថា «ហេតុអ្វីភ្លើងនឹងឆេះនៅអស់កល្បជានិច្ច ហើយដង្កូវមិនដែលស្លាប់ដូច្នេះ (ប្រៀបធៀបៈ ម៉ាកុស ៩:៤៧-៤៨) បើសិនគោលបំណងរបស់ពួកវាត្រូវបានបញ្ចប់ហើយ?»

យើងគួរតែកត់សំគាល់ផងដែរថា មានបទគម្ពីរជាច្រើនដែលពាក្យភាសាក្រិកបានបកប្រែ «សម័យ» មានន័យថា «អស់កល្បជានិច្ច» ដូចបទគម្ពីរជាច្រើនដែលប្រើពាក្យនេះដើម្បីនិយាយអំពីពេលវេលាដែលកាន់តែមានកំណត់។ ការពិភាក្សានេះមិនបានសម្រេចចិត្តទៅលើការពិភាក្សារបស់ភាគីទាំងសង្ខាងនោះទេ។ យើងក៏ត្រូវតែប្រយ័ត្នប្រយែងផងដែរនៅពេលយើងគិតអំពីទណ្ឌកម្មសម្រាប់បាបរបស់យើង។ បាបដ៏ធំត្រូវទទួលទណ្ឌកម្មដ៏ធំហើយបាបដ៏តូចត្រូវទទួលទណ្ឌកម្មដ៏តូច ប៉ុន្តែមនុស្សឆ្លាតបានការបញ្ឆោតខ្លួនឯងហើយស្មានថា បាបរបស់គេមានទំហំតិចតួចប៉ុណ្ណោះ ដូច្នេះយើងងាយយល់ខុសអំពីទណ្ឌកម្មដែលសមនឹងបាបរបស់ខ្លួន។ លោក ខាសុន សួរថា ភាពធំសម្បើមនៃអំពើបាបរបស់យើងគឺពឹងផ្អែកទៅលើឋានៈរបស់យើងផ្ទាល់ «ឬពឹងផ្អែកទៅលើកំរឹតនៃអំពើបាបដែលប្រឆាំងនឹងព្រះ ដែលមានអធិបតីភាពគង់លើសពីលោកិយ»។[១៦]លោក ចន ផៃភ័រ និយាយថា ការសំខាន់ «គឺថា ទំហំទោសកំហុសរបស់យើងមិនអាស្រ័យថា អ្នកធ្វើខុសនឹងមនុស្សម្នាក់យូរប៉ុណ្ណានោះទេ ប៉ុន្តែអាស្រ័យទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សដែលអ្នកធ្វើខុសនោះមានកំពស់ប៉ុណ្ណាវិញ»។[១៧] អំពើបាបរបស់យើងសមនឹងទទួលការដាក់ទណ្ឌកម្មគ្មានដែនកំណត់ ដោយសារសិរីល្អគ្មានដែនដំណត់របស់ព្រះអង្គដែលយើងបានធ្វើបាបទាស់នឹងទ្រង់។

អ្នកខ្លះនិយាយថា បើសិនមានការរងទុក្ខនៅក្នុងស្ថាននរកអស់កល្បជានិច្ច នោះមានន័យថា ព្រះមិនសម្រេចបានជ័យជំនះគ្រប់លក្ខណ៍លើអំពើបាបនិងការអាក្រក់នោះទេ។ ប៉ុន្តែការអះអាងនេះខកខានក្នុងការដឹងថា ព្រះជាម្ចាស់មិនបានប្រព្រឹត្តអំពើអយុត្តិធម៌ទាល់តែមានបាបណាមួយដែលទ្រង់មិនដាក់បានទណ្ឌកម្ម។ ការបន្តមាននៅរបស់ស្ថាននរកនិងអ្នករស់នៅក្នុងនោះបង្ហាញយ៉ាងល្អពីសិរីល្អនៃសេចក្តីបរិសុទ្ធរបស់ព្រះនិងការជំទាស់ដ៏សុចរិតរបស់ទ្រង់ចំពោះការអាក្រក់។

ប្រហែលនៅពេលយើងគិតអំពីការធ្វើបាបមិនចេះចប់ធ្វើឲ្យយើងមិនសូវអាក់អន់ចិត្តចំពោះការដែលព្រះដាក់ទណ្ឌកម្មមិនចេះចប់ផងដែរ។ បើសិនអស់អ្នកនៅក្នុងស្ថាននរកមិនដែលឈប់ធ្វើបាប នោះតើហេតុអ្វីពួកគេគួរតែឈប់រងទុក្ខ?[១៨]បើសិនមនុស្សបង់ថ្លៃពេញលេញសម្រាប់អំពើបាបរបស់ពួកគេនៅក្នុងស្ថាននរកហើយពួកគេឈប់ធ្វើបាប នោះតើហេតុអ្វីព្រះ

មិនអាចនាំពួកគេទៅក្នុងស្ថានសួគ៌បាន (គំនិតនេះកំពុងធ្វើឲ្យស្ថាននរកក្លាយទៅជាស្ថានជំរះបាប)? បើសិនអំពើបាបរបស់ពួកគេមិនទាន់បានសងថ្លៃពេញលេញនៅក្នុងស្ថាននរកនោះទេតើព្រះអាចមានយុត្តិធម៌ហើយធ្វើឲ្យពួកគេសាបសូន្យបានទេ?

ចុងក្រោយគឺម៉ាថាយ ២៥:៤៦ និងវិវរណៈ ២០:១០-១៥។ អ្នកចលនាដំណឹងល្អទាំងអស់ជឿថាសាតាំងគឺជាបុគ្គលម្នាក់ដែលចេះទាំងគិតនិងមានអារម្មណ៍។ ដូច្នេះ នយ៉ាងហោចណាស់វាជាម្នាក់ដែលរងទុក្ខទារុណកម្មដឹងខ្លួនអស់កល្បជានិច្ច។ «ប្រហែលជាយើងមិនមានអារម្មណ៍អាណិតអាសូរខ្លាំងទៅចំពោះសាតាំង ដូចជាអារម្មណ៍អាណិតអាសូររបស់យើងដែលមានទៅចំពោះមនុស្សជាតិនោះទេហើយយើងអាចនិយាយថា សាតាំងអាក្រក់ជាងមនុស្សជាតិណាៗទាំងអស់។ ប៉ុន្តែការពិភាក្សាដែលត្រូវបានគេប្រើដើម្បីនិយាយថា ការដែលមនុស្សរងទុក្ខអស់កល្បជានិច្ចនៅក្នុងស្ថាននរកគឺជាការមិនយុត្តិធម៌ ក៏អាចត្រូវបានគេប្រើដើម្បីនិយាយថា ការដែលសាតាំងរងទុក្ខអស់កល្បជានិច្ចនៅក្នុងស្ថាននរកគឺជាការមិនយុត្តិធម៌ដែរ»។[១៩]

## *ស្ថានសួគ៌នៅលើផែនដី*

សេចក្តីសង្ឃឹមនាពេលអនាគតរបស់ពួកគ្រីស្ទបរិស័ទគឺជាផែនដីថ្មី។ គោលបំណងចុងក្រោយរបស់ព្រះក្នុងការប្រោសលោះរាស្ត្ររបស់ទ្រង់តែងតែបានរួមបញ្ចូលទាំងការស្តាររបស់សព្វសារពើឡើងវិញ។ ដូចជាយើងបានកត់សំគាល់ខាងលើហើយថា «នគរព្រះ» សំដៅជាដំបូងទៅលើការគ្រប់គ្រងរបស់ព្រះលើរាស្ត្ររបស់ទ្រង់។ ដូច្នេះ ការជឿនិងការទទួលបាននគរព្រះគឺជាការចុះចូលចំពោះអធិបតីភាពរបស់ព្រះ។ ម្យ៉ាងវិញទៀត ការគ្រប់គ្រងរបស់ព្រះបានមកផែនដីតាមប្រវត្តិសាស្ត្រ។ ដូច្នេះ យើងមិនអាចនិយាយអំពីនគរព្រះដោយមិនគិតអំពីសេចក្តីសន្យាអំពីទឹកដីដែលព្រះបានប្រទានឲ្យពួកព្វយុកោតាំងពីដំបូងនោះទេ។[២០]

អ្នកខ្លះជឿថា ទឹកដីបានធ្វើជានិមិត្តរូបអំពីព្រះពរខាងវិញ្ញាណនៅលើស្ថានសួគ៌ដែលឥឡូវនេះកំពុងត្រូវបានបំពេញសំរេចដោយពួកជំនុំ ឬនឹងត្រូវបានបំពេញសម្រេចនៅក្នុងពេលវេលាដែលនឹងមកដល់ ដូច្នេះហើយ ទឹកដីកាណាននៅលើផែនដីមិនមែនជាមរដកអស់កល្បជានិច្ចនោះទេ ប៉ុន្តែជាគំរូនៃកន្លែងខាងវិញ្ញាណនៅលើស្ថានសួគ៌នាពេលអនាគតមួយ។

ប៉ុន្តែលោក ឡាដ់ រំលឹកយើងយ៉ាងមានប្រយោជន៍ថា «សេចក្តីប្រោសលោះនៅក្នុងព្រះគម្ពីរតែងតែរួមបញ្ចូលផែនដី»។[២១] មានអ្នកចលនាដំណឹងល្អជាច្រើនជឿថា ការបំពេញសម្រេចសេចក្តីសន្យាអំពីនគរព្រះនៅលើផែនដីគឺជាអំឡុងពេលមួយពាន់ឆ្នាំ បន្ទាប់ពីការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទ ប៉ុន្តែនៅមុនការចាប់ផ្តើមសណ្ឋានអស់កល្បជានិច្ច (វិវរណៈ ២០:១-១០)។ ពេលវេលាមួយពាន់ឆ្នាំនេះនឹងជាពេលវេលានិងកន្លែង (យ៉ាងហោចណាស់ជាការចាប់ផ្តើម) ដែលសេចក្តីសន្យានៅក្នុងព្រះគម្ពីរសញ្ញាចាស់អំពីការគ្រប់គ្រងលើរាស្ត្ររបស់ទ្រង់នៅលើផែនដី នឹងត្រូវបានបំពេញសម្រេច។

គឺតាមរបៀបនេះដែលនគរព្រះក៏អាចត្រូវបានបើកសំដែងនៅក្នុងប្រវត្តិសាស្ត្រ ជាទីបន្ទាល់សម្រាប់ជ័យជំនះចុងក្រោយរបស់ទ្រង់លើអំណាចរបស់អំពើបាបនិងសេចក្តីងងឹត។ អ្នកផ្សេងទៀតជឿថា សេចក្តីសន្យារបស់ហោរាក្នុងព្រះគម្ពីរសញ្ញាចាស់អំពីការគ្រប់គ្រងរបស់ព្រះលើរាស្ត្ររបស់ទ្រង់នៅក្នុងទឹកដីនឹងត្រូវបានបំពេញសម្រេចនៅក្នុងផែនដីថ្មីដែលចាប់ផ្តើមសណ្ឋានអស់កល្បជានិច្ច។ យោងតាមទស្សនៈនេះ សេចក្តីសន្យាក្នុងព្រះគម្ពីរសញ្ញាចាស់អំពីរាជ្យរបស់ព្រះមែស៊ីក្នុងចំណោមរាស្ត្ររបស់ព្រះនៅក្នុងទឹកដីនឹងត្រូវបានបំពេញសម្រេចតាមន័យត្រង់។ ទោះយ៉ាងណា វានឹងមិនត្រូវបានបំពេញសម្រេចនៅលើផែនដីដែលមិនទាន់បានប្រោសលោះក្នុងបច្ចុប្បន្ននេះទេ ប៉ុន្តែនៅលើផែនដីថ្មីដែលវិវរណៈ ២១-២២ បានបរិយាយវិញ។

បទគម្ពីរក្នុងព្រះគម្ពីរសញ្ញាចាស់ដែលទាក់ទងនឹងផ្ទៃមេឃថ្មីនិងផែនដីថ្មីគឺអេសាយ ៦៥:១៧-២៥ (សូមមើលផងដែរ ៦៦:២២)។ វាជាការសំខាន់ក្នុងការកត់សំគាល់ថា បទគម្ពីរនេះគឺជាបញ្ហាមួយសម្រាប់ទស្សនៈអវសានវិទ្យាទស្សនៈដែលថាព្រះយេស៊ូវត្រឡប់មកផែនដីមុនអំឡុងពេលសន្តិភាពមួយពាន់ឆ្នាំ ទស្សនៈដែលថាព្រះយេស៊ូវនឹងត្រឡប់មកផែនដី

ក្រោយអំឡុងពេលសន្តិភាពមួយពាន់ឆ្នាំ ឬសម័យនេះគឺជាសហស្សវត្ស។ ការពិបាកគឺនៅក្នុងខ. ២០ និង២៣។ ទីនោះនិយាយថា ក៏នឹងលែងមានកូនតូចដែលរស់នៅ តែប៉ុន្មានថ្ងៃ ឬមនុស្សចាស់ដែលមិនបានរស់នៅឲ្យពេញកំណត់អាយុតទៅទៀត ដ្បិតអ្នកណាដែលស្លាប់ក្នុងអាយុមួយរយឆ្នាំ នោះគេនឹងរាប់ថាជាក្មេងទេ ហើយមនុស្សបាបណាដែលរស់ដល់ត្រឹមនោះមួយរយឆ្នាំ នឹងត្រូវបណ្តាសាវិញ (ខ. ២០) ហើយនៅក្នុងខ. ២៣ និយាយថា មនុស្សនៅគ្រានោះនឹងបង្កើតកូន។ បើសិនអេសាយកំពុងបរិយាយអំពីសណ្ឋានអស់កល្បជានិច្ច ហើយការលើកឡើងរបស់គាត់អំពីផ្ទៃមេឃថ្មីនិងផែនដីថ្មីបង្ហាញថាគាត់កំពុងបរិយាយអំពីសណ្ឋានអស់កល្បជានិច្ចមែន នោះពួកគ្រីស្ទបរិស័ទទាំងអស់ត្រូវតែព្យាយាមពន្យល់អំពីមូលហេតុដែលនាំឲ្យរាស្ត្ររបស់ព្រះស្លាប់ បង្កើតកូន...ល. នៅក្នុងផ្ទៃមេឃថ្មីនិងផែនដីថ្មី។

យើងអាចរកជំនួយដើម្បីឆ្លើយតបចំពោះបញ្ហានេះតាមរយៈរបៀបកាត់ស្រាយលើអក្សរសាស្ត្ររបស់ហោរាៈ

> ពួកហោរាបានប្រកាសទំនាយដោយប្រើរូបភាពដែលអ្នកស្តាប់(អ្នកសហសម័យ)អាចយល់បាន។ នោះត្រូវនិយាយថា ពាក្យទំនាយត្រូវបានកំណត់តាមស្ថានភាពវប្បធម៌និងប្រវត្តិសាស្ត្រដែលហោរានិងមនុស្សបានរស់នៅក្នុងសម័យនោះ...(ដូច្នេះ) ពួកហោរាពិពណ៌នាអំពីនគរនាពេលអនាគតដោយពិពណ៌នាអំពីការគ្រប់គ្រងរបស់ព្រះដែលអ៊ីស្រាអែលធ្លាប់ឃើញ (ជាពិសេសរាជ្យរបស់ដាវីឌនិងសាឡូម៉ូន)ប៉ុន្តែហោរាបានប្រកាសនិមិត្តមួយដែលប្រសើរជាង គឺនគរដែលធំជាងនិងពោរពេញដោយសិរីល្អ។ ដូច្នេះ អនាគតត្រូវបានពណ៌នាដូចជាបទពិសោធន៍របស់ពួកគេក្នុងអតីតកាល ប៉ុន្តែមានភាពឥតខ្ចោះទាំងក្នុងន័យមនុស្សសហសម័យរបស់ហោរាបានដឹងនិងចូលចិត្ត។ អនាគតត្រូវបានពណ៌នាដូចជានគរព្រះនៅអតីតកាល ប៉ុន្តែមានការប្រសើរឡើង។[២២]

គំនិតរបស់លោក ហ្គាលីងថន់ Garlington គឺថា យូរៗម្តងពួកអ្នកនិពន្ធក្នុងព្រះគម្ពីរសញ្ញាចាស់និយាយអំពីអនាគតក្នុងន័យជារូបភាពនិងទស្សនៈនៅក្នុងសង្គមនិងវប្បធម៌ដែលគាត់និងពួកអ្នករស់នៅសម័យរបស់គាត់បានស្គាល់។ អ្នកនិពន្ធមិនអាចយល់យ៉ាងច្បាស់ថា ពាក្យសំដីរបស់គាត់ត្រូវបានបំពេញសំរេចក្នុងរយៈពេលយូរណាមួយនៅអនាគតនោះទេ។ ដូច្នេះ គាត់មិនអាចប្រមើលទុកជាមុនយ៉ាងច្បាស់លាស់អំពីពិភពលោកថ្មីដែលបានផ្លាស់ប្រែដោយការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទនោះដែរ។ ដូច្នេះ ហោរាប្រើសេចក្តីជំនឿ សេចក្តីភ័យខ្លាច និងសេចក្តីសង្ឃឹមរបស់មនុស្សដែលបានរស់នៅក្នុងសម័យរបស់គាត់ ដើម្បី ពន្យល់អំពីសិរីល្អរបស់ផ្ទៃមេឃថ្មីនិងផែនដីថ្មី។ ដូច្នេះ នៅពេលពួកហោរានិយាយអំពីអនាគតនោះពួកគេអាចប្រើពាក្យដែលមាននៅក្នុងអតីតកាលនិងបទពិសោធន៍ពេលបច្ចុប្បន្នរបស់ពួកគេ ដូចជាៈ ទឹកដី, ក្រឹត្យវិន័យ, ទីក្រុងយេរូសាឡឹម, ព្រះវិហារ, ប្រព័ន្ធថ្វាយយញ្ញបូជា និងការងារជាសង្ឃ។[២៣]

បទទំនាយទាំងនេះដែលបានប្រកាសដោយប្រើបទពិសោធន៍របស់មនុស្សនៅក្នុងសម័យរបស់ពួកគេ។ ជារឿយៗនឹងត្រូវបានបំពេញសម្រេចក្នុងរបៀបមួយដែលលើសជាងនិងធំជាងបទពិសោធន៍របស់ពួកគេទៅទៀត។

ដូច្នេះ របៀបមួយដែលអ្នកនិពន្ធដើមរបស់បទទំនាយនេះអាចប្រកាសអំពីសិរីល្អរបស់ផ្ទៃមេឃថ្មីនិងផែនដីថ្មីទៅកាន់មនុស្សដែលបានទទួលតែអ្វីដែលព្រះបានបើកសំដែងដល់ត្រឹមចំនុចនោះក្នុងប្រវត្តិសាស្ត្រនៅក្នុងព្រះគម្ពីរសញ្ញាចាស់ គឺត្រូវបរិយាយអំពីផ្ទៃមេឃថ្មីនិងផែនដីថ្មីដូចជាគំរូប្រសើរបំផុតនៃស្ថានភាពបច្ចុប្បន្នរបស់ពួកគេ។[២៤] អេសាយបានសរសេរអំពីពេលវេលាអនាគតដែលមានមនុស្សម្នាក់ស្លាប់នៅអាយុមួយរយឆ្នាំដែលគេគិតថាជាក្មេងម្នាក់។ ការអះអាងនេះអាចចូលទៅក្នុងចិត្តរបស់មនុស្សដែលរស់នៅក្នុងសម័យរបស់អេសាយ។

ព្រះគម្ពីរសញ្ញាថ្មីពង្រីកផ្ទៃរឿងអំពីផ្ទៃមេឃថ្មីនិងផែនដីថ្មីនេះយ៉ាងធំវាជាចំណុចកណ្តាលនៃការដែលព្រះស្ការរបស់សព្វសារពើឡើងវិញ។ យើងឃើញផ្ទៃរឿងនេះយ៉ាងច្បាស់ជាដំបូងនៅក្នុងព្រះគម្ពីរហេព្រើរ១១ ហើយបន្ទាប់មកនៅក្នុងវិវរណៈ ២១-២២។ ហេព្រើរ ជំពូក ១១ និយាយថា នៅពេលអ័ប្រាហាំបានមកដល់ទឹកដីសន្យា គាត់គ្រាន់តែជាអ្នកដទៃស្នាក់នៅក្នុង «ប្រទេសដទៃ» បណ្តោះអាសន្នប៉ុណ្ណោះ (ហេព្រើរ ១១:៩, ១៣)។ បើសិនយើងសួរថា «តើគាត់អាចទទួលយកទឹក

ដីនេះជាមរដកបានដោយរបៀបណានៅពេលដែលគាត់មិនបានមានសិទ្ធិធ្វើជាម្ចាស់ផងនោះ?» នោះបទគម្ពីរឆ្លើយថា «ពីព្រោះលោករង់ចាំក្រុងមួយដែលមានឫសជញ្ជាំង ដែលទ្រង់ជាអ្នកគូរ ហើយជាជាងសង់» (ខ. ១០)។

នេះគឺជាទីក្រុងដែលព្រះបានរៀបចំសម្រាប់ពួកគេ (ហេព្រើរ ១១:១៦) ដែលបានលើកឡើងម្តងទៀតនៅក្នុងហេព្រើរ ១២:២២ ជា «ទីក្រុងនៃព្រះដ៏មានព្រះជន្មរស់ គឺជាទីក្រុងយេរូសាឡឹមនៃស្ថានសួគ៌»។ យើងអានក្នុង១៣:១៤ ម្តងទៀតឃើញថា «នៅស្ថាននេះ (គឺជានៅលើផែនដីនាពេលបច្ចុប្បន្ននេះ) យើងរាល់គ្នាគ្មានទីក្រុងណាដែលស្ថិតនៅជាប់ជានិច្ចទេ តែយើងកំពុងស្វែងរកក្រុងនោះដែលត្រូវមក»។ ទីក្រុងនេះពិតប្រាកដជាសំដៅទៅលើទីក្រុងយេរូសាឡឹមនៃស្ថានសួគ៌នៅក្នុងហេព្រើរ ១២:២២ ដែលជាទីក្រុងដែលមានឫសជញ្ជាំង (ហេព្រើរ ១១:១០)។

យើងអានក្នុងវិវរណៈ ជំពូក២១ យើងឃើញថា យ៉ូហាន «បានឃើញទីក្រុងបរិសុទ្ធ ដែលជាទីក្រុងយេរូសាឡឹមថ្មី កំពុងចុះពីស្ថានសួគ៌មក អំពីព្រះ»(ខ. ៩-១១)។ ដូច្នេះ ហេតុផលដែលអ័ប្រាហាំជាអ្នកស្នាក់នៅបណ្តោះអាសន្ននិងជាអ្នកដទៃនៅក្នុងទឹកដីកាណានគឺថា គាត់បានមើលឃើញទឹកដីនៃផែនដីជាគំរូនៃទឹកដីឬប្រទេសនៃស្ថានសួគ៌ដែលសំខាន់ជាង។ ការផ្តោតរបស់សេចក្តីសន្យានៅក្នុងព្រះគម្ពីរសញ្ញាចាស់គឺលើទឹកដី ប៉ុន្តែផ្តោតលើទឹកដីនៃស្ថានសួគ៌ (ឬ «ស្រុក» ហេព្រើរ ១១:១៦) របស់ផែនដីថ្មីជាមួយចំនុចកណ្តាលរបស់វា គឺជាទីក្រុងយេរូសាឡឹមថ្មី។

ដោយព្រះបានសន្យាចំពោះអ័ប្រាហាំអំពីទឹកដីកាណានពីដំបូង នោះគាត់បានប្រមើលទុកជាមុនអំពីការបំពេញសម្រេចដ៏គ្រប់លក្ខណ៍និងអស់កល្បជានិច្ចរបស់វានៅក្នុងយេរូសាឡឹមនៅស្ថានសួគ៌។ អ័ប្រាហាំគឺជាអ្នកស្នងមរដក មិនត្រឹមតែទទួលបានទឹកដីកាណាននោះទេ ប៉ុន្តែទទួលបានលោកិយផងដែរ (រ៉ូម ៤:១៣)។ យោងតាមហេព្រើរ ១១:៩-១០ អ័ប្រាហាំរំពឹងចង់បានព្រះពរឥតខ្ចោះនិងនៅជាដរាបមួយនៅក្នុងទីក្រុងនៅស្ថានសួគ៌ ហើយសេចក្តីសង្ឃឹមនេះបានជួយឲ្យគាត់ចុះចូលយ៉ាងអត់ធ្មត់ចំពោះទុក្ខលំបាកនិងការធ្លាក់ទឹកចិត្តក្នុងអំឡុងពេលដំណើរធម្មយាត្រារបស់គាត់នៅក្នុងទឹកដីកាណាន។

សេចក្តីសង្ឃឹមនេះត្រូវបានបញ្ជាក់អះអាងម្តងទៀតនៅក្នុងហេព្រើរ ១១:១៣-១៦។ ពួកព្ធយុកោបានទទួលស្គាល់«ខ្លួនគេជាអ្នកដទៃដែលគ្រាន់តែសំណាក់នៅផែនដីប៉ុណ្ណោះ» (ខ. ១៣)។ ពួកគេបានស្លាប់ដោយមិនបានទទួលសេចក្តីសន្យា គឺគ្រាន់តែបានមើលឃើញពីចំងាយ។ សេចក្តីសង្ឃឹមចុងក្រោយរបស់ពួកគេមិនបានផ្តោតលើការទទួលបានមរដកនៅលើផែនដីដូចជាពេលនេះទេ ប៉ុន្តែបានផ្តោតលើ «ស្រុកមួយដ៏ប្រសើរជាង គឺខាងស្ថានសួគ៌វិញ» (ខ. ១៦)។

វិវរណៈ ជំពូក២១-២២ បានបើកសំដែងអំពីជីវិតដែលបានលើកតម្កើងនៅក្នុងផ្ទៃមេឃថ្មីនិងផែនដីថ្មីនៅក្នុងរូបភាពមួយដ៏ល្អ។ យើងមានកន្លែងទំនេរសម្រាប់តែការសង្ខេបខ្លីមួយអំពីជីវិតដែលពេញដោយសិរីល្អអស់កល្បជានិច្ចរបស់យើងនៅចំពោះវត្តមានរបស់ព្រះប៉ុណ្ណោះ។

ទំនាក់ទំនងរវាងផែនដីបច្ចុប្បន្ននេះនិងផែនដីថ្មីគឺជាការបន្តនិងការមិនបន្តមួយ(គឺមានន័យថា ផែនដីថ្មីជាផែនដីនេះប៉ុន្តែបានធ្វើជាថ្មី) ដូចមានក្នុងរវាងបច្ចុប្បន្នកាលនិងអនាគតកាលរបស់យើងនូវរូបកាយពុករលួយ និងរូបកាយឧត្តមដែលមិនពុករលួយ។ នៅក្នុងស្ថានសួគ៌យើងនឹងនៅតែដូចជាមនុស្សដែលជាយើងនៅឥឡូវនេះ ប៉ុន្តែបានផ្លាស់ប្រែ។ ផ្ទៃមេឃនិងផែនដីនាពេលអនាគតក៏ «ថ្មី» (kainos) ជាពាក្យដែលធម្មតាបានបង្ហាញអំពីភាពថ្មីរបស់គុណភាព មិនមែនជាពេលវេលានោះទេ។

ភាពខុសគ្នាមួយគឺជាស្នាព្រះហស្តថ្មីមិនមានសមុទ្រនោះទេ។ ជាធម្មតាសមុទ្រជានិមិត្តរូបនៃការអាក្រក់ ភាពវឹកវរ និងអំណាចដែលបានប្រយុទ្ធប្រឆាំងនឹងនគរព្រះ (សូមមើលយ៉ូប ២៦:៧-១៣; អេសាយ ១៧:១២, ១៣, ២៧:១, ៥១:៩-១០, ៥៧:២០; យេរេមា ៤៦:៧-១២; វិវរណៈ ១៧:៨, ២១:១)។ ដូចដែលលោក ឡាដ់ បានកត់សំគាល់ហើយថា នៅក្នុងសម័យបុរាណ សមុទ្រ «បានតំណាងឲ្យអាណាចក្រនៃសេចក្តីងងឹង សេចក្តីអាថ៌កំបាំង និងសេចក្តីគ្រោះថ្នាក់» (ប្រៀបធៀបៈ ទំនុកដំកើង ១០៧:២៥-២៨; អេសេគាល ២៨:៨; ដានីយ៉ែល ៧:៣...)។[២៥] នៅពេលយ៉ូហានសរសេរថា ស្នា

ព្រះហស្តថ្មីមិនមានសមុទ្រ នោះទ្រង់កំពុងមានបន្ទូលថា នឹងលែងមានអស់ទាំងការអាក្រក់ សេចក្តីពុករលួយ សេចក្តីមិនជឿ និងសេចក្តីងងឹតនៅក្នុងស្ថានសួគ៌ព្រះហស្តថ្មីទៀតហើយ។

ភាពពេញលេញនៃវត្តមានរបស់ព្រះក្នុងចំណោមរាស្ត្ររបស់ទ្រង់មានន័យថា ការរងទុក្ខគ្រប់ប្រភេទនៅក្នុងស្ថានព្រះហស្តចាស់លែងមានទៀតហើយ។ លទ្ធផលដែលធ្វើឲ្យខូចដោយសារអំពើបាបបានបាត់ទៅជារៀងរហូត (វិវរណៈ ២១:៣-៤)។ ទឹកភ្នែកដែលមានសេចក្តីទុក្ខព្រួយនិងការឈឺចាប់និងកំហុសសីលធម៌ដែលបានបង្ករឲ្យមាននឹងកន្លងបាត់ទៅ (នេះបំពេញសម្រេច អេសាយ ២៥:៨)។ សេចក្តីស្លាប់នឹងកន្លងបាត់ទៅ ពីព្រោះព្រះនឹងបំបាត់អំពើបាបដែលជាប្រភពរបស់វាចោលចេញ។ សេចក្តីសោកសង្រេង សេចក្តីយំទួញ និងទុក្ខលំបាកនឹងបានកន្លងបាត់ទៅ។ បទពិសោធន៍ទាំងនេះដែលជារបស់ «សេចក្តីពីមុន» ដែលយើងមានឥឡូវនេះ «បានកន្លងបាត់ទៅហើយ»។

យេរូសាឡឹមថ្មីមាន «សិរីល្អរបស់ព្រះ» (វិវរណៈ ២១:១១)។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះវិហារគឺជាកន្លែងដែលមានសិរីល្អរបស់ព្រះ និងការបើកសំដែងសិរីល្អរបស់ទ្រង់ ហើយនៅក្នុងស្ថានព្រះហស្តថ្មី វត្តមានរបស់ព្រះនឹងគង់នៅក្នុងរាស្ត្រទ្រង់និងនៅជាមួយរាស្ត្ររបស់ទ្រង់។ អវត្តមានរបស់ពេល «យប់» (វិវរណៈ ២១:២៥ខ) បង្ហាញថា មានការចូលទៅចំពោះវត្តមានរបស់ព្រះដោយគ្មានអ្វីរារាំង ហើយ នឹងលែងមានភាពងងឹតដែលធ្វើឲ្យពន្លឺចែងចាំងនៃសិរីរុងរឿងរបស់ព្រះស្រអាប់ទៀតហើយ។ វិវរណៈ ២២:៥ បង្រៀនអំពីអវត្តមានរបស់ភាពងងឹតគឺអាស្រ័យលើការបន្តបំភ្លឺដែលព្រះអង្គទ្រង់ផ្ទាល់ប្រទានឲ្យ។

នៅក្នុងវិវរណៈ ២២:១ យើងរកឃើញឧទាហរណ៍ខ្លះៗដែលយ៉ូហានភ្ជាប់ចុងបញ្ចប់នៃប្រវត្តិសាស្ត្រទៅនឹងដើមដំបូងនៃប្រវត្តិសាស្ត្រ។ ការធ្វើឲ្យគ្រប់លក្ខណ៍ចុងក្រោយគឺមានលក្ខណៈតាមការចាប់ផ្តើមដំបូង។ ចុងបញ្ចប់មិននាំឲ្យយើងត្រឡប់ទៅដើមដំបូងនោះទេ «ប៉ុន្តែដើមដំបូងប្រាប់ជាមុនអំពីគោលបំណងរបស់ព្រះ។ ប៉ុន្តែផែនដីថ្មីនិងផ្ទៃមេឃថ្មីល្អប្រសើរជាងផែនដីដំបូងនិងផ្ទៃមេឃដំបូងគ្រប់យ៉ាង ដូចជាយើងមើលឃើញក្នុងកថាខ័ណ្ឌនេះ»។[២៦]លោកុប្បត្តិ ជំពូក៣ ប្រាប់អំពីស្ថានបរមសុខដែលបានបាត់បង់ ហើយវិវរណៈ ជំពូក២២ ប្រាប់អំពីស្ថានបរមសុខត្រូវបានមកវិញ។ ស្ថានសួគ៌ (នៅលើផែនដី) បានសម្រេចគោលបំណងរបស់ព្រះអង្គដែលយើងឃើញនៅសួនច្បារអេដែន។

ហើយតើយើងនឹងធ្វើអ្វីនៅស្ថានសួគ៌? យើងនឹងបម្រើព្រះ (វិវរណៈ ២២:៣)។ យើងនឹងមើលឃើញព្រះ (ខ. ៤ក សូមមើលនិក្ខមនំ ៣៣:២២; ម៉ាថាយ ៥:៨; យ៉ូហាន ១៧:២៤; ១ធីម៉ូថេ ៦:១៦; ១យ៉ូហាន ៣:១-៣)។ យើងនឹងរីករាយជាមួយនឹងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយទ្រង់ (វិវរណៈ ២២:៤ខ)។ យើងនឹងនៅ ចំពោះព្រះវត្តមានរបស់ទ្រង់ (ខ. ៥ក, ប្រៀបធៀបៈ ជនគណនា ៦:២៤-២៦)។ យើងនឹងសោយរាជ្យនៅអស់កល្បជានិច្ច (វិវរណៈ ២២:៥ខ)។

## *ការសន្និដ្ឋាន*

យើងបានឃើញថា អ្វីដែលពួកគ្រីស្ទបរិស័ទតែងតែហៅថា «ស្ថានសួគ៌» គឺជាជីវិតអស់កល្បជានិច្ចក្នុងវត្តមានរបស់ព្រះនៅលើផែនដីថ្មី។ ដូចដែលសេចក្តីថ្លែងការណ៍អំពីសេចក្តីជំនឿបញ្ជាក់ច្បាស់ហើយថា គឺនៅ ទីនោះហើយដែល «ព្រះនឹងជាគ្រប់ទាំងអស់ក្នុងគ្រប់ទាំងអស់ ហើយរាស្ត្ររបស់ទ្រង់នឹងចាប់អារម្មណ៍លើសេចក្តីបរិសុទ្ធរបស់ទ្រង់ដែលរកបរិយាយមិនបាន ហើយគ្រប់យ៉ាងនឹងសរសើរតម្កើងដល់ព្រះគុណដែលប្រកបដោយសិរីល្អរបស់ទ្រង់»។ លោក យ៉ូណាថាន អេតវឺត Jonathan Edwards ធ្វើការសន្និដ្ឋានបានយ៉ាងល្អថាៈ

> បើសិនជាយើងអាចរៀនបានអ្វីអំពីលក្ខណៈរបស់ស្ថានសួគ៌ចេញពីព្រះគម្ពីរ។ នោះសេចក្តីស្រលាញ់និងអំណរដែលពួកបរិសុទ្ធមាននៅទីនោះ គឺធំធេងយ៉ាងអស្ចារ្យ ហើយវាទាក់ទាញចិត្តដោយមនោសញ្ចេតនាដ៏ខ្លាំង សេចក្តីទន់ភ្លន់ដែលរកពណ៌នាមិនបាន ធ្វើឲ្យពួកគេដូចជាអណ្តាតភ្លើង។ តើមានអ្នកណានិយាយថា ពួកបរិសុទ្ធនៅក្នុងស្ថានសួគ៌ដែលមើលឃើញព្រះភ័ក្ររបស់ព្រះវរបិតារបស់ពួកគេ និងសិរីល្អរបស់អង្គប្រោសលោះរបស់ពួកគេ ហើយសញ្ជឹង

គិតអំពីការងារដ៏អស្ចារ្យរបស់ទ្រង់ ជាពិសេសការដាក់ព្រះជន្មចុះរបស់ទ្រង់ជំនួសពួកគេ មានចិត្តដែលមិនប៉ះពាល់ដោយគ្រប់ការដែលពួកគេមើលឃើញនិងគិតពិចារណាដែរឬទេ?[២៧]

# កំណត់

១. ខគម្ពីរយោងដែលត្រូវបានដកស្រង់ចេញពីព្រះគម្ពីរខ្មែរបរិសុទ្ធ (១៩៥៤).

២. N. T. Wright, Jesus and the Victory of God (Minneapolis: Fortress Press, 1996), 204.

៣. Ibid., 223.

៤. George Eldon Ladd, The Presence of the Future (Grand Rapids, MI: Eerdmans, 1974), 139; emphasis in original.

៥. Ibid., 151.

៦. Ibid., 165.

៧. Ibid., 227–29.

៨. George Eldon Ladd, Crucial Questions about the Kingdom of God (Grand Rapids, MI: Eerdmans, 1952), 131–32, emphasis added.

៩. មានហេតុផលពីរសម្រាប់ការនេះ។ ទីមួយ «ទីលំនៅ» ឬ «វិមាន» នៅក្នុង២កូរិនថូស ៥:១[ខ] ទាក់ទងជាមួយ «ត្រសាល» នៅក្នុងខ. ១[ក]។ ដោយព្រោះត្រសាលសំដៅទៅលើរូបកាយនៅលើផែនដីដែលមិនទាន់ទទួលបានសិរីល្អ នោះវាសមហេតុសមផលដែលយើងសន្និដ្ឋានថា «ទីលំនៅ» ឬ «វិមាន»សំដៅទៅលើរូបកាយនៅស្ថានសួគ៌ដែលទទួលបានសិរីល្អ។ ទីពីរ ការពណ៌នានៅក្នុងខ. ១[ខ] («មិនមែនធ្វើនឹងដៃ» «នៅជាប់អស់កល្បជានិច្ច» និង «នៅលើស្ថានសួគ៌») ទំនងជាបរិយាយអំពីរូបកាយដែលទទួលបានសិរីល្អ (ជាពិសេសសូមមើល ១កូរិនថូស ១៥:៣៥-៤៩)។ គំនិតរបស់ប៉ុលគឺថា រូបកាយនៅស្ថានសួគ៌របស់យើងគឺមិនអាចត្រូវវិនាសបានទេ មិនអាចពុករលួយឬរលាយបានឡើយ។

១០. Philip Edgcumbe Hughes, Paul′s Second Epistle to the Corinthians (Grand Rapids, MI: Eerdmans, 1973), 174.

១១. Murray Harris, The Second Epistle to the Corinthians (Grand Rapids, MI: Eerdmans, 2005), 406.

១២. Ibid., 405.

១៣. Ibid., 406.

១៤. លោក ខាសុន D. A. Carson ផ្តល់ដំណោះស្រាយខ្លីដែលមានប្រយោជន៍ចំពោះបញ្ហានេះនៅក្នុង The Gagging of God (Grand Rapids, MI: Zondervan, 1996), 515–36.។

១៥. Ibid., 525.

១៦. Ibid., 534.

១៧. John Piper, Let the Nations Be Glad! The Supremacy of God in Missions, 2nd ed., rev. and exp. (Grand Rapids, MI: Baker Academic, 2003), 122.

១៨. សូមមើលវិវរណៈ ២២:១០-១១។ លោក ខាសុន ធ្វើអត្ថាធិប្បាយលើអត្ថបទនេះថា «បើសិនពួកបរិសុទ្ធនិងអស់អ្នកដែលប្រព្រឹត្តល្អបន្តជាបរិសុទ្ធនិងធ្វើត្រឹមត្រូវនៅក្នុងការគិតទុកជាមុនអំពីសេចក្តី បរិសុទ្ធឥតខ្ចោះដែលពួកគេនឹងអនុវត្តអស់កល្បជានិច្ចនោះ តើយើងក៏មិនគួរសន្និដ្ឋានថា មនុស្សអាក្រក់បន្តធ្វើការអាក្រក់នៅក្នុងការគិតទុកជាមុនអំពីភាពអាក្រក់ដែលពួកគេនឹងអនុវត្តអស់កល្បជានិច្ចដែរឬ?

១៩. Ibid., 527.

២០. See the promise as given to Abraham (Gen. 12:1–3; 13:14–17; 15:7; 17:8), and in turn to Isaac (Gen. 26:1–5), Jacob (Gen. 28:13–14; 35:12), and Moses (Ex. 6:4, 8; 13:5–11; 32:13; 33:1; Num. 10:29; cf. Num. 11:12; 14:23; 32:11; Deut. 12:8–11).

២១. Ladd, The Presence of the Future, 59. In this regard, see esp. Matt. 5:5 and Rev. 5:10.

២២. Donald Garlington, ‶Reigning with Christ: Revelation 20:1–6 and the Question of the Millennium,″ in Reformation and Revival Journal, vol. 6, no. 2 (1997): 61; emphasis in original.

២៣. លោក គ្រីស្តូហ្វឺ រ៉ៃត Christopher Wright បង្រៀនគំនិតនេះនៅក្នុង ‶A Christian Approach to Old Testament Prophecy Concerning Israel,″ in Jerusalem Past and Present in the Purposes of God, ed. P. W. L. Walker (Cambridge: Cambridge University Press, 1992).

២៤. លោក ប៊ីល G. K. Bealeរំលឹកយើងថា «អ្នកនិពន្ធនៃព្រះគម្ពីរបានកាត់ស្រាយអត្ថបទព្រះគម្ពីរដែលបានចែងទុកពីមុន ហើយការកាត់ស្រាយរបស់គេបានបន្ថែមអត្ថន័យ។ ការកាត់ស្រាយបន្ទាប់មកនេះអាចបង្កើតអត្ថន័យដែលអ្នកនិពន្ធសម័យមុនអាចមិនបានដឹង ប៉ុន្តែដែលមិនប្រឆាំងនឹងគោលបំណងដើមរបស់ពួកគេនោះទេ ប៉ុន្តែអាច «បន្ថែម» នឹងគោលបំណងរបស់អ្នកនិពន្ធសម័យមុន។ នេះមានន័យថា ទំនាយមានអត្ថន័យបន្ថែមដែលអ្នកនិពន្ធឥតដឹងប៉ុន្តែព្រះជាម្ចាស់ដឹង។ ដូច្នេះការបំពេញសម្រេចជារឿយៗ «បន្ថែម» សេចក្តីលំអិតទៅលើទំនាយដែលសូម្បីតែហោរាក៏មិនអាចបានដឹងផងដែរ»។

២៥. George Eldon Ladd, A Commentary on the Revelation of John (Grand Rapids, MI: Eerdmans, 1972), 276.

២៦. G. R. Beasley-Murray, The Book of Revelation (Greenwood, SC: Attic Press, 1974), 330.

២៧. Jonathan Edwards, Religious Affections, The Works of Jonathan Edwards, ed. John E. Smith (New Haven, CT: Yale University Press, 1969), 2:114.